# ២១. សភាទុច្ចរិត

ក្នុងកាលកន្លងទៅហើយ មានសត្វភេពីរជាសម្លាញ់នឹងគ្នាយ៉ាងស្និទ្ធ ៗ បណ្ដាភេទាំងពីរនោះ ភេមួយជាអ្នកដើររកស៊ីតាមមាត់បឹង ភេមួយទៀតជាអ្នកដើររកស៊ីក្នុងទឹកជ្រៅៗ ក្នុងថ្ងៃមួយ សត្វទាំងពីរបានត្រីមួយ ៗ ភេមួយនិយាយថា ខ្ញុំចង់ស៊ីផ្នែកខាងលើ; ភេមួយទៀតក៏ថា ខ្ញុំចង់ស៊ីដូច្នោះដែរៗ សត្វទាំងពីរពុំបានពិចារណារកការខុសត្រូវ ក៏ទាស់ទែងគ្នា, ហើយនាំគ្នាទៅកាន់លំនៅសត្វចចកមួយ ៗ ដល់ហើយក៏ក្រាបតាមរឿងរ៉ាវ ហើយពោលថា "សូមលោកមេត្តាជំនុំជំរះក្ដីឲ្យយើងខ្ញុំផង" ៗ

សត្វចចក ក៏និយាយឲ្យភេទាំងពីរ ស្ថិតនៅក្នុងពាក្យប្ដេជ្ញារបស់ខ្លួន ហើយក៏កាត់ក្បាលត្រីមួយផ្នែក កន្ទុយមួយផ្នែក ដាក់ដោយឡែកពីគ្នា រួចនិយាយថា "អ្នកដើរតាមមាត់បឹង ត្រូវបានកន្ទុយ; អ្នកមុជទឹកជ្រៅ ត្រូវបានក្បាល,

ការធ្វើយ៉ាងនេះទើបយុត្តិធម៌ ។ រីឯខ្ញុំ ដែលជាអ្នកវិនិច្ឆ័យ ត្រូវបានសាច់កណ្ដាល ។ គេទាំងពីរក៏នឹកស្ដាយក្រោយពន់ពេក ។ តាំងពីថ្ងៃនោះមក ក៏លែងទាស់ទែងគ្នា កាលណាបានត្រីមក បែងចែកស្មើភាគគ្នាស៊ីចិញ្ចឹមជីវិតតទៅ ។

## ៣. ពាក្យពន្យល់

សភា= (ម.ថ.សៈ–) ន. កន្លែងប្រជុំ, ទីសម្រាប់ប្រជុំពិភាក្សាកិច្ចការ, សមាគម ។

ទុច្ចរិត= (ម.ថ. ទុច-ចៈរិត) គុ. ដែលមិនត្រឹមត្រូវ, ដែលអាក្រក់សាមាន្យ ។

ជំនុំជំរះ = កិ. ពិភាក្សាកាត់ទោស ។

ក្ដី= ន. ដំណើរដែលទាស់គ្នាដល់ទីតុលាការវិនិច្ឆ័យ ។

ពាក្យប្ដឹង= ន. ពាក្យដែលកំរិតទុក, ពាក្យដែល

បានសន្យាទុក ។

យុត្តិធម៌= (ម.ប.យុត្តិ-ធំរ)ន. ធម៌ដែលគួរគាន់, សេចក្តីទៀងត្រង់, ការប្រព្រឹត្តិត្រឹមត្រូវ ។

វិនិច្ឆ័យ= (ម.ប.វិនិច-ឆៃ) កិ. ជំនុំជំរះអធិករណ៍, ជំរះក្តី, កាត់ក្តី (Juger) ។

១. អក្ខរាវិរុទ្ធ

ទុច្ចរិត-សុចរិត

ចំណាំ.– ពាក្យពីរព្យាង្គឬច្រើនព្យាង្គ, កាលបើព្យាង្គខាងដើមជាឃោសៈ, ព្យាង្គខាងចុងច្រើនតែតម្រួត,

ដូចជា:

ទុច្ចរិត= សរសេរជាៈ ទ + ុ + ច + ្ច + រ + ិ + ត ។

បើព្យាង្គខាងដើម ជាអឃោស, នោះគេមិនតម្រួតព្យាង្គ

ខានចុនឡើយ,

ដូចជា:

សុបរិត = សរសេរជា: ស + ុ + ប + រ + ិ + ត ។

## ស្និត-ស្និទ្ធ

ស្និត = ន. សំណុំផ្លែចេកមួយចង្កោម, ឧទា. ចេកពីរស្និត (ស្និតចេកនេះ សរសេរជា: ស + ្ន + ិ + ត ។

ស្នីត = ន. ក្រាសមួយយ៉ាងមានធ្មេញញឹក (ស្និតសិតសក់) ។

ស្និទ្ធ = (ម.ថ. ស្និត) គុ. ដែលជាទីស្រឡាញ់, ជាទីពេញចិត្ត; ល្អិតល្អ (មិត្រជាទីស្និទ្ធស្នាល) ។

# ២២. សារលិខិតរបស់មហាត្មៈគន្ធី

ផលប្រយោជន៍ដ៏សំខាន់ដែលប្រទេសឥណ្ឌា បានបំពេញក្នុងកិច្ចការធ្វើពិភពលោកឲ្យបានសន្តិសុខ គឺសេចក្តីខ្វះខ្វង់នៃប្រទេសនេះ ចំពោះការទាមទារយកសេរីភាព ដោយប្រើមធ្យោបាយដោយសន្តិវិធីនិងយុត្តិធម៌ ៗ តើសភាពប្លែកអស្ចារ្យបែបនេះនឹងមានមកក្នុងកាលជាអនាគតមែន ឬ? បើតាមពិតនូវហេតុផលសព្វគ្រប់, ប្រហែលជាមាន ៗ បើតាមសេចក្តីពិត គំនិតដែលស្មាននេះ តែងជួបប្រទះនឹងឧបសគ្គផ្សេងៗ មករាំងរាមិនខាន, ហើយខ្ញុំជឿជាក់ថា គំនិតដែលស្មានរបស់ខ្ញុំ ចំពោះអនាគតនៃមនុស្សជាតិនោះ មានស្ថាន-ភាពជ្រៅឆ្ងាយទូលាយពន់ពេក ទោះតែខ្ញុំមិនយល់ដោយជាក់លាក់នូវលទ្ធផលជាអវសាន, សេចក្តីជឿពិតរបស់ខ្ញុំនោះ ក៏ជាប្រទេសឥណ្ឌា ដែលនឹងបានសេរីភាពតទៅអនាគត ដោយៈប្រើមធ្យោបាយជាសន្តិវិធីនិងយុត្តិធម៌, មិនត្រូវយក

មធ្យោបាយផ្សេងពីខាងលើនេះមកអនុវត្តទេ ។

ព្រោះហេតុដូចនេះ, សូមលោកដែលមានជំនឿឬឧត្តម-គតិដូចខ្ញុំ ព្យាយាមជួយឧបត្ថម្ភប្រទេសឥណ្ឌា ឲ្យបានអនុវត្តទៅតាមជំនឿ ឬ ឲ្យបានសម្រេចទៅតាមឧត្តមគតិខាងលើនេះទៅអនាគត ។

## គ. ពាក្យពន្យល់

សារលិខិត= (ម.ថ.សារៈ-) ន. សំបុត្រដ៏សំខាន់, សំបុដ ដែលមានខ្លឹមសារ ។

មហាត្មៈគន្ធី= (ម.ថ. ម-ហា-ត្មៈ-គ័នធី) ន. ឈ្មោះមហាបុរសមួយរូបរបស់ប្រទេសឥណ្ឌា ។

ពិភពលោក= ន. លោកទាំងមូល, សកលលោក ។

សន្តិសុខ= (ម.ថ.សន់-) ន. សេចក្តីសុខដែលកើតអំពីសេចក្តីស្ងប់, សេចក្តីសុខយ៉ាងសោះសូន្យ ។

សេរីភាព= (ម.ថ. –ភាប) ន. អំណាចដែលអាចធ្វើអ្វីបាន

តាមអំពើចិត្ត, អំណាចពេញទី (liberté) ។

មធ្យោបាយ= (ម.ថ. ម័ត-ធ្យោបាយ) ន. ឧបាយជាគ្រឿង

ដឹកនាំទៅកាន់សេចក្ដីបរិបូណ៌តាមផ្លូវកណ្ដាល (moyen) ។

សន្ដិវិធី= (ម.ថ. សន់-តិ–) ន. របៀបយ៉ាងស្ងប់, វិធីដែល

សម្រាប់ប្រើដោយផ្លូវឥតកំរើកំរើល ។

យុត្តិធម៌= (ម.ព.ក្នុងអត្ថបទលេខ ៦១).

អស្ចារ្យ= (ម.ថ.អស់-ចារ) គុ. ដែលគួរស្ញើចក្រៃពេក,

ដែលគួរស្ងើងយ៉ាងលើសលប់ ។

អនាគត= (ម.ថ. អ:-នា-គត់) កាលឬសម័យខាងមុខ

(Avenir) ។

ឧបសគ្គ= (ម.ថ.អ៊ុប៉ៈស័ក) ន. ឧបទ្រព, គ្រឿងទើស

ទាក់, គ្រឿងរារាំងដំណើរ (obstacle) ។

ស្ថានភាព = (ម.ថ.—ន:—) ន. ទីតាំង, ភាពនៃកន្លែង ;
ដំណើររបស់ហេតុការណ៍ ។

លទ្ធផល = ន. ផលដែលបានស្រេចស្រេចហើយដោយល្អ ។

អវសាន = (ម.ថ. អ:វ:—) ន. ទីបំផុត, ទីបប់, ចុងបំផុត,
ចុងក្រោយបង្អស់ (final) ។

អនុវត្ត = (ម.ថ. អ:នុវ័ត) កិ. ធ្វើ, ប្រើ, ប្រព្រឹត្ត ។

ឧត្តមគតិ = (ម.ថ. អ៊ុត—ដំគ:តិ) ន. គំនិតដ៏ថ្លៃថ្លា, គតិដ៏ល្អ ។

ឧបត្ថម្ភ = (ម.ថ. អ៊ុប៉ុត—ថ័ម) កិ. ទំនុកបំរុង, គាំទ្រ, ទល់—
ទ្រ, ជ្រោមជ្រែង ។

ពន្យោមទ្រង់

១. អក្ខរាវិរុទ្ធ

អំពីស្រៈ ិ ម្ន ាំ—ម

ពាក្យណាដែលមានស្រៈ ិ ប្រកបអក្សរ ម ខាងចុង,
ច្រើនតែសរសេរទីងស្រៈ ឹ ,

*ដូចជា:*

ត្រីក្រឹម, ជ្រៃក្រឹម, ឈើខ្លឹម, មើមខ្ញឹម, ញញឹម, ទាទឹម, ទឹមគោ, តឹមតង្គល, ថ្ងឹមគ្នា, សត្បឹម, ស្នឹម ។ល។

*ប៉ុន្តែមានសរសេរជា ិ + ម ខ្លះដែរ*

*ដូចជា:*

រិម, ស្និម, ស្រិម ។ល។ *តែទោះជាយ៉ាងណាក៏ដោយក៏នៅតែអាចសរសេរទឹង ឹ + ម ជាដរាបដែរ ។ វៀរលែងតែពាក្យនោះជាពាក្យបាលីឬសំស្ក្រឹត,*

*ដូចជា:*

ពិម្ពឬពុម្ព, សិម្ពលី, និម្មានរតី, ប្រិមប្រិយ ។ល។

# ២៣. ឫទ្ធិមហាត្មៈគន្ធី

នៅប្រទេសឥណ្ឌៀ មានសភាពផ្សេងពីប្រទេសដទៃ; បុគ្គលិកលក្ខណៈ, កិច្ចរស់នៅដោយសុចរិត, ការប្តូរជីវិតរបស់ខ្លួនជាសភាពដែលគេពេញចិត្តជាងគតិឬគំនិត ៗ ក្នុងប៉ុន្មានឆ្នាំមុននេះ ឧត្តមគតិលោកគន្ធី បានចូលទៅស្ថិតនៅក្នុងសាច់ឈាមពួកប្រជារាស្ត្រហិណ្ឌូ គ្រប់ជាន់ថ្នាក់; ឧត្តមគតិនោះជាឧត្តមគតិរបស់ជាតិ ដែលដុះក្នុងសន្តានចិត្តគ្រប់ ៗ គ្នា, តែគុណភាពនិងសេចក្តីរាប់អាននៃពួកប្រជារាស្ត្រ មកពីបុគ្គ-លិកលក្ខណៈរបស់លោក; ឥឡូវនេះស្ថានការណ៍នយោ-បាយប្រទេសឥណ្ឌៀ មិនត្រូវនឹងគំនិតយោបល់របស់លោក, លោកគន្ធីក៏ត្រឡប់ទៅជា ប្រឹងប្រែងខ្នះខ្នែងខាងសង្គមកិច្ចនឹងសេដ្ឋកិច្ចទៅវិញ ៗ តែជាការភ័ន្តច្រឡំដោយពិត បើយើងស្គាល់ថាសមត្ថភាពរបស់លោក ខាងផ្លូវនយោបាយហិណ្ឌូជាវត្ថុអតីតៈ សមត្ថភាពនឹងពលភាពនោះ ស្ថិតនៅ

ផងដែល ហើយបើមានកិច្ចការខាងនយោបាយ ល្អមទឹង ប្រព្រឹត្តទៅបាន លោកក៏សំដែងអានុភាពរបស់លោកក្នុង ពេលនោះមិនខាន; លោកកម្រទឹងចាត់ការពេញលេញ តែ បើការនោះ ត្រូវបំពេញដោយករណីយកិច្ចដ៏ប្រសើរ លោក ក៏ទឹងធ្វើដោយម៉ឺងម៉ាត់ ។

## ៣. ពាក្យពន្យល់

លទ្ធិ = (ម.ព. ក្នុងអត្ថបទលេខ ៣៧) ។

សភាព = (ម.ព. ក្នុងអត្ថបទលេខ ៣ ) ។

បុគ្គលិកលក្ខណៈ (ម.ព. ក្នុងអត្ថបទលេខ ២៣) ។

សុចរិត = (ម.ថ. សុច:រិត ) ន. ការប្រព្រឹត្តល្អ, សេចក្ដី- ប្រតិបត្តិត្រឹមត្រូវ

គតិ = (ម.ព. ក្នុងអត្ថបទលេខ ៣៧) ។

ឧត្ដមគតិ = (ម.ព. ក្នុងអត្ថបទលេខ ២២) ។

ស្ថិតនៅ = កិ. តាំងនៅ, ដំកល់នៅ ។

ប្រជារាស្ត្រហិណ្ឌូ = ពពួករាស្ត្រជាតិឥណ្ឌៀទាំងមូល ។

សន្តានចិត្ត = (ម.ថ. សន់-ដាន-) ន. ចិត្តគំនិតអធ្យាស្រ័យ

គុណភាព = (ម.ថ. គុណៈភាព) ន. ភាពនៃគុណ, គុណ
ប្រយោជន៍ទូទៅ ។

ស្ថានការណ៍ = (ម.ថ. – ការ) ន. ហេតុការណ៍, រឿង
រ៉ាវ, ហេតុនៃទីតាំង ។

នយោបាយ = ន. ឧបាយជាគ្រឿងដឹកនាំ (politique) ។

សង្គមកិច្ច = (ម.ថ. ស័ង–គំមៈកិច) ន. កិច្ចការក្នុង
សង្គម (action social) ។

សេដ្ឋកិច្ច = (ម.ថ. សេត–ថៈកិច្ច) ន. កិច្ចការប្រសើរ
បំផុត, មុខរបរដ៏ឧត្តម, មុខការរបរដែលមានប្រយោជន៍ដ៏
សំខាន់ក្នុងប្រទេសនីមួយៗ (économie) ។

សមត្ថភាព = (ម.ថ. សៈម័ត-ថៈភាព) ន. ភាពនៃសេចក្ដីអាចឃាន, ភាពនៃសេចក្ដីមោះមុត ។

អតីត = (ម.ថ. អៈឌិត) គុ. ដែលកន្លងទៅហើយ, ដែលហួសទៅហើយ ។

ពលភាព = (ម.ថ. ពៈលៈភាប) ន. កំឡាំងកំហែង ។

អានុភាព = (ម.ថ. -ភាប) ន. អំណាច, តេជះ, សេចក្ដីអង់អាច, សេចក្ដីក្លាហាន ។

ករណីយកិច្ច = (ម.ថ. កៈ-រ៉ៈណីយៈកិច) ន. កិច្ចដែលគួរធ្វើ, ការងារដែលត្រូវធ្វើ (devoir) ។

## ១. អក្ខរាវិរុទ្ធ

## រស- រស់- រ៉ស់- រួស

រស = (ម.ថ. រស់) ន. សម្ផស្ស (អាហារនេះមានរសឆ្ងាញ់) ។

រស់ = កិ. មានជីវិតនៅ (រស់នៅមួយរយឆ្នាំ បើមានសេចក្ដី

ប្រមាទ លោកហៅថារស់នៅឥតអំពើ ទុកស្មើដូចស្លាប់ទៅហើយ) ។

រ៉ស់ = ន. ត្រីស្រកាមួយយ៉ាង (ត្រីរ៉ស់) ។

រួស = គុ. ឬ កិ.វិ. រហ័ស, ឆាប់ (មនុស្សរួសមាត់រួសក; រួសរាន់, រួសរាយ, រួសរ៉ាវ) ។

អំពីស្រៈ ិ + ញ នឹងស្រៈ េ + ញ

គិញ = ន. ចារបុរស ។

ញេញ = កិ. ខាំស្រាលៗ (ញេញមូ) ។

ទិញ = កិ. ដូរយករបស់ដែលខ្លួនត្រូវការដោយប្រាក់ (ទិញអង្ករ) ។

ទំនិញ = ន. របស់ដែលត្រូវទិញ (ទំនិញឡើងថ្លៃ) ។

ធ្មេញ = ន. អាការក្នុងមាត់សម្រាប់ខាំទំពា (ធ្មេញកណ្ដុរ, ធ្មេញក្របី, ធ្មេញត្រី) ។

ពេញ = កិ. ឬ កិ. វិ. ស្មើឡើងដល់ចំនួន, ដែលដល់ចំនួន, ដល់មាត់ : ទឹកពេញពាង; កាន់ពេញដៃ; ពេញក្រមុំ; បំពេញវិជ្ជា ។

មិញ = និ. វេលា : កាលនោះមិញ, អម្បាញ់មិញ ។

រិញ ៗ = កិ. វិ. ដែលហូរតិចៗ : ទឹកហូររិញៗ ។

រេញ = គុ. ទេញ, ក្រិស, លូតលាស់បំរើនមិនរួច : សំទូងរេញ, ឫស្សីថ្នាំងរេញ ។

លិញ = ន. ទាហាន ។

លិញគិញ = ន. ទាហានសម្ងាត់, ចារបុរស ។

លេញ = ន. ឈ្មោះត្រីមួយប្រភេទ (ត្រីលេញ) ។

វិញ = និ. ទៀត, ដូចដែល (ត្រឡប់មកវិញ) ។

វេញ = កិ. ត្រដាញ់បញ្ចូលផ្គុំ (វេញខ្សែ, វេញគំនិតគ្នា) ។

## ២៤. សេដ្ឋកិច្ចប្រទេសឥណ្ឌាសម័យមហាត្មៈគន្ធី

បើចង់យល់ច្បាស់នូវស្ថានការណ៍ប្រទេសឥណ្ឌា, គេត្រូវយល់ហេតុការណ៍ពិតប្រាកដ នៃស្ថានភាពលោកមហាត្មៈគន្ធី ដោយហេតុថា អានុភាពនៃបុគ្គលិកលក្ខណៈរបស់លោក គួរជាទីជ្រះថ្លាសម្បើមអស្ចារ្យ ទាល់តែមិនយូរប៉ុន្មាន, លោកអាចណែនាំឲ្យប្រជាជនយល់ហើយធ្វើតាមលោក, ប្រតិបត្តិតាមលទ្ធិឧត្តមគតិរបស់លោកៗលោកជាដួងវិញ្ញាណចំពោះប្រជាជាតិឥណ្ឌាទាំងមូល អាចញុំាងឲ្យមនុស្សទាំងប្រទេសចលាចលបាន ៗ ពួកមេនយោបាយឯទៀតច្រើនចូលមកជិតលោកទឹងយកលោកជាបង្អែក; លោកក៏បានពន្យល់បំភ្លឺអ្នកទាំងនោះ ឲ្យប្រតិបត្តិតាមមតិនយោបាយសេដ្ឋ-កិច្ចរបស់លោក យកមតិនេះទៅអប់រំជនជាតិឥណ្ឌា ក្នុងភូមិនិគមជនបទ ឲ្យធ្វើតាមកម្មវិធីខ័តដារ ៗ កម្មវិធីនេះ គឺលោកប្រើនយោបាយគ្រប់បែប មានការធ្វើបេរ

តម្បាញវៃកប្បាសនៅតាមភូមិ ទឹងនិយមប្រើតែសំពត់កប្បាស ដែលធ្វើខ្លួនឯងមកស្លៀកពាក់; ពាក្យ "ទ័តដារ" ប្រែថា "សំពត់អំបោះតម្បាញនៅគ្រឹហាខ្លួន" ។

ឥ. ពាក្យពន្យល់

សេដ្ឋកិច្ច=(ម. ព. កន្ធអត្ថបទលេខ ២៣) ។

សម័យ=(ម. ព. កន្ធអត្ថបទលេខ ៣៧) ។

ស្ថានការណ៍=(ម. ព. កន្ធអត្ថបទលេខ ២៣)។

ស្ថានភាព=(ម. ព. កន្ធអត្ថបទលេខ ២៧)

អានុភាព=(ម. ព. កន្ធអត្ថបទលេខ ២៣)

បុគ្គលិកលក្ខណៈ=(ម. ព. កន្ធអត្ថបទលេខ ២៣) ។

បលាបល=(ម.ថ. បៈលា៉-បល់) កិ. ជ្រួលជ្រើម, រំជើប

រំជួល ។

មតិ=(ម.ថ. មៈតិ) ន. សេចក្ដីយល់ឃើញ, គំនិត ។

កម្មវិធី=(ម.ថ.ក័ម-ម:-) ន. របៀបនៃការងារ (programme) ។

ត្រីបារ= ន. ផ្ទះ (villa) ។

១.អក្ខរាវិរុទ្ធ

អំពីស្រះ ិ + ប និងស្រះ ែ + ប

គគ្រិប= គុ. ដែលមានអាការគ្រិប ៗ ដោយដង្កូវបុះ (ដង្កូវបុះគគ្រិប) ។

គ្រែប= កិ. បៀសវាង (ចោរគេចពីប៉ូលីស) ។

គ្រិប ៗ = កិ. វិ. ដែលកំរើកញាប់ៗ (ដង្កូវបុះគ្រិបៗ) ។

គ្រែប= ន. ឈ្មោះឈើមួយយ៉ាង (ដើមគ្រែប) ។

គ្រែប= គុ. ឬកិ. ដែលក្ងាត់សរសៃ (ដៃគ្រែប, គ្រែបជើង) ។

ឃ្លុប= ន. ឈ្មោះក្របមួយយ៉ាង (ក្របឃ្លុប) ។

ល្ហេប= កិ. ចាប់ប្រញាប់ដើម្បីឲ្យបែក (ល្ហេបបែ) ។

ញ្ញេប= កិ. សង្កត់ល្មេចបំពៀច (ញេបសង្កើប) ។

ទ្រុប= កិ. ចុចចាក់ដោយទ្រនិប (ឃ្មុំទិច, ខ្មួយទិច) ។

ទ្រនិប= ន. អវយវៈស្រួចមុតមានពិស (ទ្រនិបឃ្មុំ) ។

ឆ្មេប= កិ. បិទក្លុក (ធ្វើការកុំឆ្លេបក្លក) ។

និប្ប= (ម.ថ. និប) គុ.ឬ កិ.វិ. មិនដែលដាប់ (នៅដាប់ដានិប្ប) ។

ប្រទេប= កិ. ដេរប្ញុបប្រញាប់ឲ្យវិនាស (ប្រទេបផ្កាសា) ។

ពន្លិប= កិ. ធ្វើឲ្យលេប (ពន្លិបទុក) ។

ពពិប= គុ. ដែលសើមក្រខ្វក់ខ្វាំង (ដីសើមពពិប) ។

ពពេប្ប= ន. ឈ្មោះសត្វស្លាបមួយយ៉ាង (សត្វ

ពពេច) ។

ពេបរ័ន= (ម.ថ. ពេច) ន. ពាក្យស័ដី (ពាក្យ

ពេចន៍) ។

ព្រិប= កិ. ញាក់ទទាក់ស្ងាប (និយាយចំពោះលលក

ឈ្មោល) លលកព្រិប ។

## ២៥. របៀបសូត្រសុន្ទរកថា

មុនដំបូងត្រូវរៀនហាត់ទឹក ឬ ហាត់សូត្រ ត្រង់សេចក្តីដែលគួរបញ្ចេញបញ្ចូលតែម្នាក់ឯងឲ្យស្ទាត់ជាមុនសិន សឹមចូលទៅសូត្រក្នុងទីប្រជុំតូច-ធំ ៗ ពេលដែលសូត្រនោះ ត្រូវសូត្រមួយៗឲ្យច្បាស់ៗឲ្យពេញសម្លេង តែកុំឲ្យជ្រុលដល់ទៅស្រែក ត្រូវលៃឲ្យល្មមដល់សំឡេង កុំឲ្យតឹងពេក ធូរពេក កុំឲ្យញាប់ពេក រន្ទើលពេក ឲ្យមានវគ្គមានឃ្លា, ត្រូវកាន់ស្មារតីនឹងកាន់ឫកពាជាអ្នកនឹងធឹង, កុំវាសដៃផ្ងារឡើងនឹងផ្កាប់ចុះ, កុំក្រមាច់លេង, កុំសើចខ្លួនឯងនាំឲ្យសាបឫកពា, បើចង់សើចខ្លាំងទប់ពុំបាន ត្រូវបន្អង់សូត្រមួយស្របក់សិន ដល់ស្រួលខ្យល់ សឹមសូត្រតទៅទៀត, ត្រូវតាំងចិត្តថា អ្នកស្តាប់ទាំងអស់សុទ្ធតែនៅក្រោមអំណាច ឬ ក្រោមឱវាទរបស់ខ្លួន, មិនត្រូវឱនឈ្ងោក ឬងើបទៅលើទេ, មិនត្រូវចោលភ្នែកឲ្យហួសពីបរិសទ្យអ្នកស្តាប់; ត្រូវធ្វើភ្នែកឲ្យរឹង អាចសម្លឹងអ្នក

ស្តាប់មិនញោច, មិនត្រូវឧបដៃទឹមចង្កេះឬប្រត់ដៃទៅលើវត្ថុផ្សេងៗ ។ ពេលក្រោកឈរក្តី អង្គុយចុះទៅវិញក្តី មិនត្រូវហោស់ស្រូកន់ពេក ឬយឺតពេកឡើយ ។

## ក. ពាក្យពន្យល់

សូត្រ=(ម ថ.សូត) កិ. ថាតាមសេចក្តីដែលសរសេរស្រាប់ៗ

សុន្ទរកថា= (ម.ថ. សុនទៈរៈកៈថា) ន. សំដីគួរចង់ស្តាប់, ពាក្យសម្រាប់ថ្លែងក្នុងសន្និបាត ។

វគ្គ= (ម.ថ.វ័ក) ន. សង្កាត់, ក្រុម, ស្មើរ ។

ស្មារតី= (ម.ថ.ស្មារដី) ន. សេចក្តីនឹកឃើញ, ការចាំបាន, សតិ ។

ក្រមាប់= កិ. កំប្លែង, ធ្វើឫកពាដូចស្វា ។

ឱវាទ= (ម.ថ.អោ-វ៉ាត) ន. ដំបូន្មាន, អនុសាសន៍ ។

បរិស័ទឬ-សទ្យ= (ម.ថ.បរុស័ត) ន. ពួកជនដែលប្រជុំ

គ្នា, ពួកជនដែលស្ម័គ្រចិត្តរួមគំនិតមកស្តាប់ប៉ូលគ្នា ។

មិនញ្ញោប= កិ. មិនទុនដោយអាការញញើត ។

១. អក្ខរាវិរុទ្ធ

ព្រិបៗ = គុ. ឬ កិ. វិ. ដែលស្រក់បុះរឿយ ៗ (ភ្លៀងរលឹមព្រិចៗ) ។

ព្រេប= កិ. ពារទឹងក្បាល, ជាន់ទឹងជើង, ចាក់ទឹងក្តុកដោយពេញកំឡាំង (ដំរី ព្រេច) ។

ព្រេប= ន. ឈ្មោះម្ហូបមួយយ៉ាង (ម្ហូបព្រេច) ។

ភ្លេប= កិ. ចាំមិនបាន (ភ្លេចមេរៀន) ។

មិប =កិ. ប៉ុប្រិចភ្នែកជាសញ្ញា (មិចភ្នែកឡោយ) ។

មិប កិ.= ប៉ិចយ៉ាងផ្ទូន់ដៃ (មិចថ្ពាល់កូនក្មេង) ។

ម៉េប ម្តេប= និ. អ្វី, យ៉ាងណា (យ៉ាងម៉េចទៅ?)

ម្រេច = ន. ឈ្មោះដំណាំមួយយ៉ាង (ដើមម្រេច) ។

វេច = គុ. ដែលស្មុះបន្តិចៗ (សំពត់វេចជាយ) ។

លិច = កិ. ចូលកប់បាត់ទៅ (ទូកលិច; ថ្ងៃលិច) ។

លិច = (ម. ថ. ឡិច) ន. ឈ្មោះទិសដែលព្រះអាទិត្យអស្តង្គត (ទិសខាងលិច) ។

លេច = កិ. ចេញពីទីកំបាំង (ស្រាប់តែឃើញលេចផ្ទឹមពីក្នុងព្រៃមក) ។

លេច = កិ. ជ្រាបហូរចេញ (ទឹកលេចពីក្អឺស្រែ) ។

លេច = កិ. លៀនចេញ (គ្រាប់ឈើដុះលេចពន្លកពីក្នុងដី) ។

លេច = កិ. ផ្លាយចេញ (លេចដំណឹង, លេចសំដី) ។

លេច = កិ. បង្ហាញមុខឲ្យឃើញ (ចុះទើបនឹងលេច

មុខមកពីណាហ្នឹង?) ។

លេប= គុ. ដែលមិនឥត (ផ្ទះលេច, ពានលេច) ។

លេប= ន. ឈ្មោះដំបៅមួយយ៉ាង (ដំបៅលេច) ។

រឹប= កិ. ទាញត្រឡប់ចុងក្តិតមុខចូលមកវិញ (រឹបដាយកន្ទេល) ។

រឹបៗ= កិ.វិ. ដែលចក់ញើយៗ (គោចក់កន្ទុយរឹបៗ) ។

រៀប= កិ. ធ្វើឲ្យជាបន្ទើប (រៀបសំពាយ, រៀបបាយសំណុំ)។

# ២៦. កែវភ្នែកនឹងកែវប្រាជ្ញា

ពន្លឺកែវភ្នែកយើងដែលភ្លឺនោះ មិនមែនភ្លឺតាមទំនើងខ្លួនឯងតែម្យ៉ាងទេ តោងអាស្រ័យពន្លឺខាងក្រៅផង បើមានតែកែវភ្នែកមិនមានពន្លឺថ្ងៃនឹងពន្លឺភ្លើងខាងក្រៅជាជំនួយផងទេ ក៏មិនអាចនឹងមើលឃើញរូបរាងអ្វីឲ្យជាក់ប្រាកដបានដែរ ឬជាមានតែពន្លឺខាងក្រៅមិនមានពន្លឺភ្នែកផង ក៏មិនអាចនឹងឃើញនូវវត្ថុទាំងពួងបានដែរ ពន្លឺកែវភ្នែកនឹងពន្លឺខាងក្រៅត្រូវអាស្រ័យគ្នាទៅវិញទៅមកជាធម្មតាទើបសម្រេចកិច្ចទៅបាន ។

ចំណែកកែវប្រាជ្ញាយើងក៏ដូចកែវភ្នែកដែរ បើមានតែពន្លឺកែវប្រាជ្ញាខាងក្នុងប៉ុណ្ណោះ ឥតមានពន្លឺខាងក្រៅជាជំនួយទេ ក៏មិនអាចនឹងដឹងការខុសត្រូវសុខទុក្ខបានឡើយ គឺថាបើមានតែប្រាជ្ញាម្នាក់ឯងមិនមានវិជ្ជាជាជំនួយ ទៅផ្ទប់ជាជញ្ជាំងកញ្ចក់ផងទេ ក៏មិនអាចនឹងឆ្លុះឲ្យដឹងការខុសត្រូវឬការអ្វីសព្វចំពូកទៅបាន ឬជាបើមានសុទ្ធតែក្បួនខ្នាតយ៉ាងច្រើនដំកល់

ទុកគុនទ្ធសព្វថ្ងៃ តែមិនយកកែវគឺបញ្ញាចក្ខុទៅរៀនសូត្រ ពិចារណារកការខុសត្រូវពិនិត្យឲ្យដឹងថាមានប្រយោជន៍ ឬឥតប្រយោជន៍ផងទេ ពន្លឺកែវគឺក្បួនខ្នាតនោះ ក៏មិនអាចនឹងសម្រេចប្រយោជន៍អ្វីតិចតួចបានឡើយ ។

គគ. ពាក្យពន្យល់

ប្រាជ្ញា= (ម.ថ. ប្រាជញា) ន. សេចក្ដីដឹងទូទៅ; សេចក្ដីដឹងដែលកើតអំពីការរៀន, ស្ដាប់, គិត; ការដឹងច្បាស់នូវសេចក្ដីពិត (intelligence) ។

ពន្លឺ= ន. សភាវៈដែលភ្លឺ; រស្មីដែលភ្លឺ ។

កែវភ្នែក= ន. វត្ថុដ៏ថ្លាស្អាតដែលនៅចំទីពាក់កណ្ដាលនៃភ្នែក ។

សុខ= ន. សេចក្ដីសប្បាយ; សេចក្ដីសម្រាន្ត; ដំណើរស្រណុក ។

ទុក្ខ= (ម.ថ.ទុក) ន. សេចក្តីព្រួយ; សេចក្តីលំបាក (កាយនឹងចិត្ត) ។

វិជ្ជា= ន. (ម.ព.កន្សែងបទលេខ១) ។

ឆ្លុប= កិ. ទប់ទ្បេងនឹង; កត់ទប់ទ្បេនៅនឹង) ។

កញ្ជក់= ន. កែវសម្រាប់ផ្ទុះស្រមោល ។

សព្វប៉ំពូក= គុ. គ្រប់មុខគ្រប់យ៉ាង ។

បញ្ញាបក្ខ= ន. (ម.ព.កន្សែងបទលេខ១៤ ។

## ១. អក្ខរាវិរុទ្ធ

## អំពីស្រៈ ុ + ប និងស្រៈ អ + ប់

អ្នកមានច្រើនតែមាន សំឡេងនេះដូចគ្នា, ឧទា. គុប់ និង គុប គឺមានស្រដៀងគ្នា ។ ដូច្នេះ នាំឲ្យអ្នកសរសេរពិបាកកំណត់ចាំណាស់ៗ តែត្រូវសង្កេតវិធីយ៉ាងឆាយដូចតទៅនេះៈ

ចំពោះព្យញ្ជនៈ «គ» គ្មានប្រើពាក្យ «គុប» (គ + ុ + ប) ឡើយ ។

«ឃ» ពាក្យតម្រួត «ឃ្ល» គ្មានប្រើពាក្យ «ឃ្លុប់» (ឃ + ្ល + ប + ់ ) យ៉ាងនេះឡើយ ។

«ង» គ្មានប្រើពាក្យ «ងុប» (ង + ុ + ប) ឡើយ ។

«ជ» គ្មានប្រើពាក្យ «ជុប» (ជ + ុ + ប) ឡើយ ។

«ឈ» » «ឈុប (ឈ + ុ + ប) ឡើយ ។

«ឈ្ង» » «ឈ្ងុប» (ឈ + ្ង + ុ + ប) ឡើយ ។

«ឈ្ល» » «ឈ្លុប» (ឈ + ្ល + ុប) ឡើយ ។

«ធ» » «ធុប» (ធ + ុ + ប) ឡើយ ។

សង្កេត.– ព្យញ្ជនៈ «ធ + ុ» នេះ, បើជាពាក្យបាលីឬសំស្រ្កឹត, គេប្រើ ធ + ុ តែព្យាង្គចុងត្រូវជាព្យញ្ជនៈ «ព» ដូចជា: ធុព្វលភាព, ធុព្ភាសិត ។ល។

«ទ្រ» គ្មានប្រើពាក្យ «ទ្រប៉» (ទ + ្រ + ប៉) ឡើយ មានតែពាក្យសំស្រ្កឹត ១ ម៉ាត់គឺៈ ទ្រព្យ តែព្យាង្គចុងក៏ជាអក្សរ ព ទៀត ។

## ២៧. ប្រាជ្ញា និងវិជ្ជា

មនុស្សដែលមានប្រាជ្ញានិងវិជ្ជានៅក្នុងខ្លួន ចាត់ថាជាមនុស្សឧត្តមខ្ពង់ខ្ពស់ជាងគេក្នុងលោកនេះ និងលោកឯទៀត ព្រោះថាធម្មតាការអ្វី ៗ ដែលជាការចម្រើនកំបាំងទាំងប៉ុន្មាន ក៏សុទ្ធតែជាកិច្ច ជាអាហារ របស់អ្នកដែលមានប្រាជ្ញានិងវិជ្ជាទាំងអស់ មិនមែនជាកិច្ចជាអាហាររបស់មនុស្សសាមញ្ញ ដែលឥតប្រាជ្ញានិងវិជ្ជានោះទេ ៗ ឯមនុស្សដែលមិនមានយោបល់និងចំណេះទាំងពីរប្រការក្នុងខ្លួនហើយ កុំថាឡើយមនុស្សបែបនោះតែម្នាក់ឯង ក្រែងមិនអាចនឹងទទួលធុរៈទាំងនោះបាន ទោះបីមានខ្លួនច្រើនរាប់រយរាប់ពាន់នាក់ក៏ដោយ ក៏មិនអាចនឹងធានាសម្រេចការដែលក្រុបចម្រើននោះបានឡើយ ៗ ឯការទាំងឡាយអំបាលនោះ សុទ្ធតែសំបាច់រង្គាន់របស់អ្នកមានប្រាជ្ញាជំរះទាំងអស់ មនុស្សបែបនេះកុំថាឡើយមានរូបច្រើននាក់ទើបអាចទទួលទ្រទ្រង់ការក្រុបចម្រើននោះបាន ដោយ

ហោចទៅសូម្បីតែម្នាក់ឯង ក៏គង់អាចធានារ៉ាប់បានពិត ៗ មិនខាន ។

ប្រាជ្ញានិងវិជ្ជាទាំងពីរប្រការនេះ ព្រះពុទ្ធដីកាទ្រង់សរសើរថាជាកែវដ៏វិសេស ជាគុណជាតិតែងធ្វើឲ្យសម្រេចនូវប្រយោជន៍គ្រប់យ៉ាងគ្រប់ចំពូកបាន នឹងថាជាទ្រព្យដ៏មានថ្លៃតែងជាប់ដៃកាន់ទៅមកជាមួយ នឹងខ្លួនក្នុងលោកនេះនិងលោកខាងមុខ ។

## ក. ពាក្យពន្យល់

បង្កៀត= គុ. ដែលមិនទូលាយ; ដែលជ្រៀតបៀត ។

មនុស្សសាមញ្ញ= មនុស្សធម្មតា; មនុស្សជាន់ធម្មតា ។

យោបល់= ន. សេចក្ដីយល់ឃើញ, ដំណើរគិតយល់, គំនិតធ្លុះយល់ ។

ប្រការ= ន. (ម. ព. ក្នុងអត្ថបទលេខ ១៦) ។

ធុរៈ= ន. ដំណើរជំពាក់ដោយកិច្ចនីមួយ ៗ

ធានា= កិ. ទទួលរ៉ាប់រងលើខ្លួន, ទទួលអះអាង ៗ

អម្បាលនោះ= និ. ទាំងអស់នោះ ៗ

សំបាប់= ន. កេរ្តិ៍ដំណែល, របស់ជាដំណែល, មត៌ក ៗ

វង្វាន់= ន. របស់ជាបំណាច់ដែលគេឲ្យដល់ជនណាមួយ

ដោយសេចក្តីពេញចិត្ត ៗ

ផ្សះ= កិ. ធ្វើឲ្យជ្រះ, ធ្វើឲ្យជាប់ស្រប, កាត់សេចក្តីសាញ ៗ

ទ្រទ្រង់= កិ. ជួយទំនុកបំរុង, កាន់កាប់រក្សា, លើកដំកើង ៗ

ដោយហោចទៅ= និ. យ៉ាងទាបបំផុត, យ៉ាងល្អិតល្អោចៗ

ពុទ្ធដីកា = (ម.ថ. ពុត-ធៈដីកា) ន. ព្រះបន្ទូលរបស់ព្រះពុទ្ធ,

ពុទ្ធវចនៈ គឺបាលីដែលជាគោលដើមនៃព្រះពុទ្ធសាសនា ៗ

សរសើរ= កិ. និយាយលើក, ពោលពណ៌នានូវគុណ

របស់នរណាមួយ, និយាយស្ញើច (admirer) ។

វិសេស= (ម.ជ. វិសេស) គុ. ប្រសើរ, ថ្លៃថ្លា, ឧត្តុង្គឧត្តម។

គុណជាតិ ឬ គុណជាតិ= (ម.ជ. គុណៈជាត) ន. គុណគ្រប់យ៉ាង ។

១. អក្ខរាវិរុទ្ធ

"ង្ហ" គ្មានប្រើពាក្យ "ង្ហុប"(ង+ ្ហ+ ុ+ប) ឡើយ ។

"ឆ" " "ឆុប"(ឆ+ ុ+ប) ឡើយ ។

"ព" " "ពប់"(ព+ប+ ់) ឡើយ ។

មានតែពាក្យប្រើនព្យាង្គ ហើយជាប់ដោយព្យញ្ជនៈដទៃជាព្យាង្គខាងដើមផង ដូចជា:

កំពប់, ជំពប់ ។ល។

"ភ" គ្មានប្រើពាក្យ "ភុប"(ភ+ ុ+ប) ឡើយ ។

"យ" គ្មានប្រើពាក្យ "យុប"(យ+ ុ+ប) ឡើយ ។

“ល” មានប្រើទាំងពីរបែប, តែមានសេចក្តីសង្កេតខុសគ្នាយ៉ាងនេះ

លប់ = ន. ប្រដាប់សម្រាប់ទាក់បក្សី (លលកព្រៃជាប់លប់; លប់សម្រាប់ដាក់ទទា) ។

លុប = កិ. ធ្វើឲ្យបាត់ស្នាម, បំបាត់មិនឲ្យមាន (លុបអក្សរ, លុបអណ្តូង) ។

លុប = កិ. លាងជំរះដោយទឹក (លុបមុខ, លុបខ្លួន) ។

លុប = កិ. គ្របលើ (សំឡេងព្យុលុបគេទាំងអស់) ។

លុប = គុ. ដែលបំបាត់គុណគេ (មនុស្សលុបគុណគេ) ។

ប៉ុន្តែ គេអាចសរសេរជា: “លប់” (ល+ប+់) យ៉ាងនេះក៏បាន ។

# ២៨. ប្រទេសខ្មែរនឹងលាវចំពោះសម្ព័ន្ធភាព ខាងទាហាន

សន្ធិសីទទទួលអាញត្តិ នូវខព្រមព្រៀងស្តីអំពីការបញ្ឈប់សង្គ្រាមនៅប្រទេសវៀតណាម ។ តាមន័យខព្រមព្រៀងនេះ មិនត្រូវឲ្យមានមូលដ្ឋានទ័ពរបស់រដ្ឋបរទេសណាអាចតាំងនៅក្នុងតំបន់ទុកឲ្យផ្តុំគ្នា របស់ភាគីទាំងសងខាងបានឡើយ ។ ភាគីទាំងពីរនេះត្រូវមើលជួនថៃ កុំឲ្យតំបន់ដែលគេចែកឲ្យខ្លួននោះ ចូលក្នុងសម្ពន្ធភាពទាហានណាមួយ ហើយនឹងកុំឲ្យយកតំបន់នោះប្រើប្រាស់ ដើម្បីបង្កើតសង្គ្រាមជាថ្មីឬក៏នឹងបំរើនយោបាយបៀតបៀនឡើយ ។

សន្ធិសីទទទួលអាញត្តិដែរ នូវសេចក្តីថ្លែងការណ៍នៃរដ្ឋាភិបាលប្រទេសកម្ពុជា នឹងប្រទេសលាវ តាមសេចក្តីថ្លែងការណ៍នេះ ប្រទេសទាំងពីរនឹងមិនត្រូវជាប់ជំពាក់ ដោយកិច្ចព្រមព្រៀងណាជាមួយនឹងរដ្ឋទាំងឡាយឯទៀតទេ ។ បើកិច្ច

ព្រមព្រៀងនោះមានការបង្ខំឲ្យចូលសម្ពន្ធភាពទាហាន ដែលមិនស្របទៅតាមគោលការណ៍ទាំងឡាយ នៃធម្មនុញ្ញសហប្រជាជាតិ, ឬចំពោះប្រទេសណាៗ ដែលមិនស្របគោលការណ៍នៃកិច្ចព្រមព្រៀង អំពីបទបញ្ឈប់សង្គ្រាមទាំងឡាយនៅប្រទេសនេះ, ឬដរាបណាសន្តិភាពរបស់ខ្លួន មិនទាន់សត្រូវមកគំរាម ដរាបនោះមិនអាចឲ្យមានមូលដ្ឋានទ័ពបរទេសមកតាំងនៅលើដែនដីខ្មែរទឹងដែនដីណាៗបានឡើយ ។

### ៣. ពាក្យពន្យល់

សម្ពន្ធភាព= (ម.ថ.សម-ព័ន-ធៈភាប) ន. ភាពនៃការទាក់ទងគ្នាទៅវិញទៅមក ។

សន្និសីទ= (ម.ថ.សន់-និសិត) ន. ការប្រជុំគ្នាដោយដំណើរអង្គុយ យ៉ាងស្ងាត់ស្ងៀម ។

អាញត្តិ= (ម.ថ.អាញ័ត) ន. សេចក្ដីបង្គាប់; ពាក្យបង្គាប់;

ខបន្តាប់ ។

ន័យ=(ម.ថ.នៃ) ន. ការណែនាំ; សេចក្ដីពន្យល់ ។

មូលដ្ឋាន= (ម.ព. ក្នុងអត្ថបទលេខ ៤០) ។

បរទេស= (ម.ថ.ប-រៈ-) ន. ប្រទេសក្រៅ; ប្រទេសដទៃ (étranger) ។

ផ្តុំគ្នា=កិ. ប្រមូលគ្នាឲ្យជាដុំ; ប្រជុំគ្នាជាដុំ ។

ភាគី=ន. (ម.ព.ក្នុងអត្ថបទលេខ៤០) ។

ថ្ននបើ=កិ. ស្ងួនរក្សាទុក; ថែរក្សាពុំឲ្យខ្ចាយ ។

សង្គ្រាម=(ម.ថ.សង់គ្រាម) ន. ចំបាំង ។

នយោបាយ=(ម.ព. ក្នុងអត្ថបទលេខ ២៨) ។

សេចក្ដីថ្លែងការណ៍=ន. សេចក្ដីប្រកាសទូទៅ; សេចក្ដីឲ្យដំណឹងជាសាកល ។

រដ្ឋាភិបាល = (ម. ថ. រ័ត..ឋា-) ន. (ម. ព. កន្សែតូច ទំព័រ លេខ១៣៩) ។

គោលការណ៍= ន. ខសេចក្ដី, ហេតុដែលជាគោលចារក; កស្ដុតាននៃច្បាប់ ។

ធម្មនុញ្ញ ឬ ធម្មនូញ= (ម.ថ. –ធ័ម–មៈ នុញ, –នូញ) ន. ឈ្មោះច្បាប់មួយក្រម សំដែងអំពីរបៀបតុលាការ ។

សហប្រជាជាតិ= (ម. ថ. សៈហៈ– ) ន. ជាតិផ្សេង ៗ គ្នាដែលរួបរួមកិច្ចព្រមព្រៀងជាមួយគ្នា ។

សន្តិភាព = (ម. ថ. សន់–តិ– ) ន. ភាពឬដំណើរស្ងប់ស្ងាត់ត្រាណ រាបទាប; ដំណើរសះជាទន់គ្នា ។

## ១. អក្ខរាវិរុទ្ធ

អំពីស្រៈ ុ + ង និង ស្រៈ អ៊ + ង់

"គុ" គ្មានប្រើពាក្យ គុង (គ + ុ + ង) ឡើយ ។

"គិរង់" គប្បីសរសេរជា: "គ + ិ + រ + ង + ់" យ៉ាងនេះតែម្យ៉ាង ។

"ឃ្លុ" គ្មានប្រើពាក្យ "ឃ្លុង" (ឃ + ្ល + ុ + ង) ឡើយ ។

"ជុ" គ្មានប្រើពាក្យ "ជុង" (ជ + ុ + ង) ឡើយ ។

"ជន្លង់" គប្បីសរសេរជា: "ជ + ន + ្ល + ង + ់" យ៉ាងនេះតែម្យ៉ាង ។

"ញុះញង់" គប្បីសរសេរជា: "ញ + ុ + ះ + ញ + ង + ់" យ៉ាងនេះតែម្យ៉ាង ។

"ទុ" មានប្រើទាំងពីរបែប, តែមានសេចក្ដីសង្កេតខុស

គ្នា យ៉ាងនេះ

ទង់= ន. ផ្ទាំងសំពត់ឬក្រដាស ដែលមានពណ៌ឬរូបផ្សេង ៗ សម្រាប់ប្រើជាកិត្តិយសក្នុងប្រទេសមួយ ៗ: ទង់ជាតិ, ទង់សាសនា, ទង់ខ្មោច, ទង់ជ័យ ។

## ពាក្យពិសេសដែលជាប់ដោយទង់

ទង្គត់, ទង់ដែង, ទង់ហ្វ៊ា ។

ទុង= ន. ឈ្មោះបក្សីមួយយ៉ាង: សត្វទុង ។

ទុងឬទុង= ឧ. សូរស៊ីមួយដែលឮខ្លាំង: កាំភ្លើងបាញ់ឮសូរទុង ៗ

## ២៩. សេចក្ដីសប្បុរស

ខ្មែរជាអ្នកកាន់ព្រះពុទ្ធសាសនា តែងប្រដៅកូនចៅឲ្យកាន់ចិត្តសប្បុរសនឹងលោកសង្ឃ នឹងស្មូមយាចក ហើយអាណិតមេត្តាដល់អ្នកកំសត់ទុគ៌តគោកយ៉ាកលំបាកផង ៗ ហេតុដូច្នេះបានជាគេឃើញខ្មែរ ឲ្យទានធ្វើបុណ្យជារឿយ ៗ ក្នុងវត្តអារាម ហើយគេជួយមនុស្សក្រីក្រគោកយ៉ាកលំបាក ឲ្យមានអាហារចិញ្ចឹមជីវិត ហើយនឹងសម្លៀកបំពាក់ល្មមសមគួរផង ៗ

ខ្មែរត្មះតិះដៀលមនុស្សណា ដែលមានចិត្តជាអសប្បុរស អកតញ្ញូនឹងអ្នកដ៏មានគុណ មានមាតាបិតាគ្រូអាចារ្យ ហើយនឹងអ្នកដែលជួយទំនុកបំរុងផងផ្ដើមឲ្យបានប្រយោជន៍ផ្សេង ៗ ជាដើម ៗ គេមិនរាប់អានមនុស្សដូច្នេះឡើយ គេស្អប់ហើយគេមិនយកជាមិត្តសំឡាញ់ទេ ៗ

ទោះជាមានសេចក្ដីទូន្មានល្អប្រកបដោយធម៌ដូច្នេះ ក៏គង់នៅមានមនុស្សខ្លះមានចិត្តកំណាញ់ ៗ មនុស្សខ្លះមិន

ដែលធ្វើបុណ្យឱ្យទានសោះ ហើយកំណាញ់នឹងខ្លួនឯងផង ។

## គ. ពាក្យពន្យល់

សេចក្ដីសប្បុរស= (ម.ថ.សប់-ប៉ូរ៉ស់) ន. សេចក្ដីល្អដែលមានប្រព្រឹត្តដោយការយកចិត្ត (charité) ។

ពុទ្ធសាសនា=(ម.ថ.ពុត-ធៈ-) ន. ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ (religion bouddhique) ។

លោកសង្ឃ= ន. អ្នកបួសក្នុងព្រះពុទ្ធសាសនា ។

សុំមឃោបក=(ម.ថ.-យាចក) ន. អ្នកសូមទានដែលក្រីក្រលំបាកគោកយ៉ាក ។

ទុគ៌ត=(ម.ថ. ទុគ៌ត) គុ. ដែលដល់នូវសេចក្ដីលំបាក; ដែលក្រីក្រទ្រព្យ, ដែលទីទាល់ក្រ ។

វត្ត=(ម.ថ.វ៉ត់) ន. អារាមជាទីនៅអាស្រ័យរបស់ពួកសមណៈ

អារាម=(ម.ថ.- រ៉ាម)ន. ប្រទេសមួយដែលនាំទឹកចិត្តឱ្យរីក-

វាយសប្បាយ; (ក្នុងទីនេះ) សំដៅសេចក្ដីថា វត្ត ។

ត្អះតិះដៀល=កិ. និយាយបន្អាប់បន្តុះដោយបញ្ជាក់អំពីទោសដែលខ្លួនមាន ។

អសប្បុរស=(ម.ថ អ:សប់-ប៉ុរស់) (ក្នុងទីនេះជា គុ.) ដែលមានចិត្តអាក្រក់, ដែលអាក្រក់ ។

អកតញ្ញូ=(ម.ថ.អ:ក:តញ់-ញូ)ន. (ក្នុងទីនេះជា គុ.) ដែលល្មើសគុណ; ដែលមិនដឹងឧបការគុណដែលគេបានធ្វើហើយ (ចំពោះខ្លួន) ។

គ្រូអាចារ្យ=ន. គ្រូដែលជាអ្នកប្រៀនប្រដៅ បង្ហឹកបង្ហឺនគំនិតមារយាទឲ្យបានត្រឹមត្រូវល្អ ។

សេចក្ដីទូន្មាន=ន. សេចក្ដីប្រៀនប្រដៅ (conseil) ។

កំណាញ់= (ក្នុងទីនេះជា កិ.) រិះស្វិតស្វាញក្នុងការចាយវាយ ។

១. អក្ខរាវិរុទ្ធ

"ទំរង់" គប្បីសរសេរជា: "ទ + ំ + រ + ង + ់"

យ៉ាងនេះតែម្យ៉ាង ។

"ទ្រ" មានប្រើទាំងពីរយ៉ាង, ប៉ុន្តែមានសេចក្ដីសង្កេតខុសគ្នា

យ៉ាងនេះ

ទ្រង់ = កិ. ប្រព្រឹត្ត, កាន់: ព្រះសង្ឃទ្រង់ធម៌; ស្ដេចទ្រង់ព្រះ

ពស្ត្រ, លោកសង្ឃទ្រង់បាត្រ ។

ទ្រង់ = បុ.ស. (រ.ស.) ព្រះអង្គ (សូមទ្រង់ប្រោសព្រះរាជទាន

អភ័យទោស) ។

ទ្រង់ = ន. ទំរង់, សណ្ឋាន, លំនាំ, ពង, រូប (តុនេះមាន

សណ្ឋានទ្រង់ត្រាយគួរឲ្យស្រឡាញ់) ។

ទ្រុង = ន. ប្រដាប់សម្រាប់ដាក់សត្វ: ទ្រុងមាន់, ទ្រុងខ្លា,

ទ្រុងត្រី ។

“ផ្អង់” គប្បីសរសេរជា “ផ+ ្អ+ង+ ់” យ៉ាងនេះតែម្យ៉ាង ។

“ផ្ទង” (ផ្ទុងត្រី) គប្បីសរសេរជា: “ផ+ ្ទ+ ង” យ៉ាងនេះតែម្យ៉ាង ។

“ផ្ធង” (បញ្ចូលផ្ធុង, ខ្សែបីផ្ធុង, មើលទៅឃើញផ្ធុង) គប្បីសរសេរជា: (ផ+ ្ធ+ ង) យ៉ាងនេះតែម្យ៉ាង ។

“ផ្គង់” (ផ្គង់ចង្ហាន់, ផ្គង់គ្រឿងប្រើប្រាស់) គប្បីសរសេរជា: “ផ+ ្គ+ង+ ់” យ៉ាងនេះតែម្យ៉ាង ។

“ព” មានប្រើទាំងពីរយ៉ាង, ប៉ុន្តែមានសេចក្ដីសង្កេតខុសគ្នាយ៉ាងនេះ

ពង់= កិ. បំពាន, បំអឹត: ក្អាកពង់ ។

ពង់= កិ· ដោររត្វាតឡើង: ពង់ខ្ទុះ ។

ពង់= កិ. (ន.ប្រ.) ក្រអឹត ក្រអោង: ប៉ុកពង់ ។

ពុង= ប. ពាក្យសម្រាប់និយាយផ្សំនឹងពាក្យពោះ: ពោះពុងៗ

ពុង= ន. ពោះ: ម្ដាយមីងខ្ញុំ, ពេលគាត់នៅផ្ទះ, គាត់ចោម

ពុង ៗ

ខ្សែពុង= ខ្សែដែលចងរឹតពោះសត្វ ៗ

# ៣០. សមាធិ

ចិន្តាជារលកថាមពល ដែលញាប់ញ័រចេញទៅក្នុង សរីរកាយ ប្រកាសចេញទៅក្រៅជាអំពើចិន្តា នឹងមានកម្លាំង ខ្លាំង ឬខ្សោយស្រេចហើយនឹងការគិត បើគិតរវើរវាយ ចិន្តា ពុំមានកម្លាំងល្មមនឹងសំដែងឲ្យឃើញប្រចក្សទេ បើគិតតែពី ចិន្តានោះដោយយកចិត្តទុកដាក់ ទើបចិន្តានោះប្រកបដោយ កម្លាំងខែងរ៉ែង រឹតញុំាងចិត្តឲ្យខែងរ៉ែងល្អគឺសមាធិ ។ សមាធិគឺការដំរង់កម្លាំងចិត្ត សំដៅចំពោះចំណុចណាមួយ ដោយមិនរវើរវាយ ឬងាកទៅរកអារម្មណ៍ ឬហេតុការណ៍ដទៃ ដែលប្រាកដនៅទីជិតខាងនោះ ។ កែវឆ្លុះដែលទាញរស្មីព្រះ អាទិត្យ ប្រមូលផ្តុំទៅលើក្រដាសមួយសន្លឹក ក្រដាសនោះក៏ ឆេះ មានសេចក្តីយ៉ាងណាមិញ ឯការប្រមូលកម្លាំងចិត្តផ្តុំទៅ ក្នុងអារម្មណ៍តែមួយ អាចឲ្យចេញពន្លឺបានក៏យ៉ាងនោះដែរ ។ ដូច្នេះ ការតាំងចិត្តជាសមាធិនាំឲ្យងាយដោះស្រាយនូវប្រស្នា

ផ្សេងៗ ឲ្យគិតការអ្វីមួយបានដោយឆាប់រហ័ស ឲ្យបេះបាត់ការបានភ្លាមៗ ឲ្យធ្វើកិច្ចការទាំងឡាយបានដោយរហ័ស ហើយល្អផងៗ សមាធិចិត្តជាលក្ខណៈនៃជនជាឯកទគ្គបុគ្គលៗ

ក. ពាក្យពន្យល់

សមាធិ= (ម.ថ. សៈម៉ា-ធិ) ន. ដំណើរស្ងប់ចិត្តស៊ប់គង់អគ្គឈាន, ការបុះចិត្តស៊ប់ឬស្ងប់ចិត្តកង់គន្ធឹងអារម្មណ៍ដែលពេញ, ការនឹករពឹងយ៉ាងស្ងប់ចិត្តៗ

ចិន្តា= (ម.ថ.ចិន-ដា) ន. សេចក្តីគិត, គំនិត (Pensé)

ថាមពល= (ម.ថ. ថាមៈពល់) ន. កំឡាំងពលំៗ

សរីរកាយ=(ម.ថ. សៈរ៉ីរ-) ន. រូបកាយទាំងស្រុង, ខ្លួនប្រាណ; កម្រង់នៃរូបៗ

ប្រកាស= កិ. ថ្លែង, សំដែងប្រាប់ឲ្យដឹងៗ

ប្របក្ប= (ម.ព.ក្នុងអត្ថបទលេខ ៣) ។

ខៃងង៉ែង= (ម.ព.ក្នុងអត្ថបទលេខ ២០) ។

អារម្មណ៍= (ម.ព.ក្នុងអត្ថបទលេខ ២១) ។

វស្សី= (ម.ព.ក្នុងអត្ថបទលេខ ១៣) ។

ប្រស្នា= ន. ចំណោទ, សេចក្តីអាថ៌កំបាំងផ្សេង ៗ ។

សមាធិចិត្ត= ចិត្តដែលមិនរវើរវាយ, ចិត្តដែលស៊ប់ស្ងួន ។

ឯតទគ្គបុគ្គល= (ម.ថ.អេតៈទ័ក-គៈបុកគល់)

ន. បុគ្គលប្រុសដែលគេលើកថាលើសលែងប្រសើរ ជាងគេខាងមុខការឬចំណេះវិជ្ជាណាមួយ ។

៧. អក្ខរាវិរុទ្ធ

"ព្រង់" (រន្ធឈើ ឬរន្ធសត្វៈ ព្រង់ជាស) គប្បីសរសេរ ជាៈ "ព + ្រ + ង + ់) យ៉ាងនេះតែម្យ៉ាង ។

“ភុង„ ( ស្បូរព្រោះដោយខ្លាយ ឬ បែកក្នុងទឹកជាដើម ) គប្បី

សរសេរជា: “ភ + ុ + ង„ យ៉ាងនេះតែម្យ៉ាង ។

“ភ្លុង„ (ធ្លាក់ក្នុងទឹកឮសូរភ្លុង) គប្បីសរសេរជា: “ភ+ ្ល + ុ + ង„ យ៉ាងនេះតែម្យ៉ាង ។

“មមង់” (សត្វមមង់នៅក្នុងផ្លែល្ហុង) គប្បីសរសេរជា:

“ម+ម+ង+ ់“ យ៉ាងនេះតែម្យ៉ាង ។

“មុង„ (ដេកក្នុងមុង) គប្បីសរសេរជា: “ម+ ុ +ង„ យ៉ាង

នេះតែម្យ៉ាង ។

“យ៉ង់„ (ថ្វាយង់) គប្បីសរសេរជា: “យ៉+ង+ ់„ យ៉ាង

នេះតែម្យ៉ាង ។

សង្កេត.– យ៉+ ុ +ង គ្មានប្រើឡើយ ។

ទោះបីពាក្យពីរព្យាង្គក្តីក៏ប្រើតែ យ៉+ង+ ់ ទាំងអស់ តែ

បំពោះតែព្យញ្ជនៈ (ឃ) នៅខាងដើម ដូចជា យង់ឃ្មង

យង់ យល់ ។ល។

បើព្យញ្ជនៈ «ឃ» នៅខាងចុងហើយជាពាក្យពីរព្យាង្គ

នោះមានសរសេរជា «ឃង់» ខ្លះ «ឃុង» ខ្លះ ដូចជា:

ប្ហឃង់ = សរសេរនឹង «ឃង់» ។

ព្រឃុង= " «ឃុង» ។

# ៣១. លទ្ធិពុទ្ធសាសនា

ក្នុងពិភពលោកនេះ មានសាស្តាចារ្យជាច្រើន ដែលជាអ្នកបង្កើតលទ្ធិសាសនាផ្សេងៗ មានពុទ្ធសាសនា, ព្រាហ្មណ៍សាសនានិងគ្រិស្តសាសនាជាដើម ។ បណ្តាសាស្តាចារ្យទាំងអម្បាលនោះ, ព្រះបរមគោតមរបស់យើង ជាអ្នកបង្កើតលទ្ធិពុទ្ធសាសនា ។ ពួកយើងជាពុទ្ធបរិស័ទបានដឹងច្បាស់ហើយថាព្រះពុទ្ធជាម្ចាស់មិនយល់ព្រមថា មានអាទិទេពមានឫទ្ធិណាមួយ អាចបង្កើតផែនដីនិងសត្វលោកនោះទេ ។ ព្រះអង្គពិចារណាឃើញច្បាស់នូវជីវភាពរបស់មនុស្សសត្វលើផែនដីនេះ សុទ្ធតែតាំងនៅក្នុងវិបរិណាមធម៌ ប្រកបដោយទុក្ខលំបាកគ្រប់យ៉ាង, មិនឋិតនៅជាស្ថាពរតាមប្រក្រតី និងមិនលុះក្នុងអំណាចរបស់ខ្លួន, មានសភាពសោះសូន្យទទេ ។

ព្រះពុទ្ធដាស់តឿនឲ្យសត្វលោកពិចារណា សេចក្តីទុក្ខគ្រប់គ្នា កុំធ្វេសប្រហែសឬលោភព្យាបាទរករឿងបង្កវិវាទរវាង

មនុស្សលោកឬសត្វជាតុទាំងពួង ។ ត្រូវប្រព្រឹត្តធម៌ជាកុ-សលទឹងមានមេត្តាចិត្តស្រឡាញ់រាប់អានគ្នាទៅវិញទៅមក ។ ក្នុងប្រវត្តិសាស្ត្រ បានបង្ហាញឲ្យឃើញភស្តុតាងស្រាប់ថា តាំងពី ២.៥០០ ឆ្នាំមកហើយ ពុំមានការបង្ហូរឈាមណាមួយដោយយកនាមព្រះពុទ្ធជា ជាអ្នកដឹកនាំនោះឡើយ ។

គ. ពាក្យពន្យល់

លទ្ធិ= (ម. ព. ក្នុងអត្ថបទលេខ ៣៧) ។

ពុទ្ធសាសនា= (ម. ព. ក្នុងអត្ថបទលេខ ២៩) ។

ពិភពលោក= (ម. ព. ក្នុងអត្ថបទលេខ ២២) ។

សាស្តាចារ្យ= (ម. ឋ..ចារ) ន. អាចារ្យជាអ្នកដឹកនាំខាងលទ្ធិសាសនា ។

ព្រហ្មញ្ញសាសនា= (ម. ឋ. ព្រំម៉ុញ-ញៈសា.ស្នា) ន. សាសនា ដែលជាប់ទាក់ទងដោយសេចក្តីប្រកាន់ជឿថា

មហាព្រហ្មជាអ្នកបង្កើតពពួកសត្វ, សាសនារបស់ពួកព្រាហ្មណ៍ (Religion brahmanique) ។

គ្រិស្តសាសនា= (ម. ថ. គ្រិស-សាស្នា) សាសនារបស់ព្រះគ្រិស្ត Réligion chrétienne ។

បរមគោតម= (ម. ថ. បរ៉ុម-គោ-ដំ) ព្រះបរមនាមនៃព្រះអរហំសម្មាសម្ពុទ្ធ ។

ពុទ្ធបរិស័ទ= (ម. ថ. ពុត-ធ បរ៉ិស័ត) ន. អ្នកកាន់សាសនាព្រះពុទ្ធ ។

អាទិទេព=ន. ទេវតាដែលជាអ្នកសាងលោក(Dieu) ។

រិទ្ធិ=(ម. ថ រឹត) ន. តេជះ, អំណាច, សេចក្ដីអង់អាច ។

សត្វលោក= (ម. ថ. សាត់–) ន. ពពួកមនុស្សសត្វដែលអាស្រ័យនៅលើផែនដី ។

ជីវិភាព= (ម. ព. កន្សែងបទលេខ ១) ។

វិបរិណាមធម៌= (ម. ថ. វិប៉ះរុណាមមៈធ័រ) ន. ធម៌ប្រែប្រួល, សភាវៈផ្លាស់ប្រែ, ដំណើរមិនទៀង ។

ស្ថាពរ= គុ. មាំមួន, រឹងប៉ឹង, ថិតថេរ, ខ្ជាប់ខ្ជួន ។

លោភ= កិ. លោភលន់ចង់បាន, ប្រាថ្នាដោយជំពាក់ចិត្ត

ព្យាបាទ= កិ. គុំគួន, ចង់គំនុំ ។

វិវាទ= ន. ជម្លោះ, ដំណើរទាស់ទែងគ្នា ។

១. អក្ខរាវិរុទ្ធ

“រ” មានប្រើទាំងពីរបែប ប៉ុន្តែមានសេចក្ដីសង្កេតខុសគ្នាយ៉ាងនេះ

រង់= កិ. បង្អង់ចាំ (រង់ចាំខ្ញុំបន្តិចសិនណា!) ។

រង់ជើង= ន. ឈ្មោះកេតពិសមួយយ៉ាង ។

រង្គ=(ម.ថ.រង់) ន. ជ័រមានសម្បុរលឿងសម្រាប់ធ្វើជា

ថ្នាំ: ជ័រត្កឹ ។

រុង= ច្រើនតែប្រើជាមួយនឹងពាក្យខាងចុងទៀតដូចជា រុងរឿង រុងរោចន៍, រុងរាំង ។ល។

“លង់” មានប្រើទាំងពីរបែប ប៉ុន្តែមានសេចក្ដីសង្កេត ខុសគ្នាយ៉ាងនេះ ។

លង់= កិ. ជ្រុល, ស៊ុន, ហួស (លង់គំនិត) ។

លង់= កិ. លេចក្នុងទឹក: លង់ទឹក ។

លង់= គុ. យូរពេក: យូរលង់ ។

ពាក្យពិសេសដែលប្រើជាប់ដោយពាក្យ លង់ លង់ទ្រ-ទេស, លង់លុះ លង់ហិត, លង្វែក ។ល។

“លង្វង់” (ធ្វាយលន្វង់លន្វាច) គប្បីសរសេរជា:

(ល+ង+ ្វ +ង+ ់ ) យ៉ាងនេះតែម្យ៉ាង ។

លុង=កិ. ដីកឲ្យកើតជារូង: លុងដី, លុងឈើ, ដីកលុង ៗ

# ៣២. ធម្មជាតិរបស់មនុស្ស

ព្រះពុទ្ធបានញែកធាតុមនុស្សហើយរកឃើញថា អាការៈក្នុងខ្លួនសុទ្ធតែជាបុគ្គល ។ ព្រះអង្គបានយកបុគ្គលនោះធ្វើជាគ្រឿងពិសោធរកសេចក្ដីពិត ។ ញែកចេញជាធាតុមានបួន អាការៈរឹងៗ ដូចជាឆ្អឹងជាដើម ហៅថាធាតុដី; អាការៈដែលទន់រាវ ៗ ដូចជាទឹកមាត់ ស្លេស្មជាដើម ហៅថាធាតុទឹក ; អាការៈដែលក្ដៅឧណ្ហ ៗ ហៅថាធាតុភ្លើង; ខ្យល់ដង្ហើមចេញចូលហៅថាធាតុខ្យល់ ។ ក្នុងកាយរបស់បុគ្គល មានអាការៈ, សម្ពស្សនិងសម្បជញ្ញៈ ។ ក្រៅពីនោះមានប្រតិកម្មរបស់វិញ្ញាណដែលធ្លាប់តែទទួលយកនូវអារម្មណ៍ទាំងឡាយ ហើយបញ្ជូនឡើងទៅឲ្យខួរក្បាល ។ បន្ទាប់ពីនោះមកមានសង្ខារ គឺការស្កស្នាញទាំងឡាយ ដែលប្រមូលផ្ដុំនៅក្នុងខ្លួន និងដួងព្រលឹង មានតណ្ហា, មុខការ, និន្នាការនិងគំនិតផ្សេង ៗ ជាដើម ។ ក្នុងចំណោមសំខារទាំងឡាយនេះ, យើងសួរ

ខ្លួនយើងមើល តើមានអ្វីជារបស់ "ខ្លួនយើង" ឬទេ? ព្រះអង្គត្រាស់ថាទេ, ឥតមានអ្វីជារបស់ "ខ្លួនយើង" ទាំងអស់ ។

## ៣. ពាក្យពន្យល់

ធម្មជាតិ= (ម.ព. ក្នុងអត្ថបទលេខ ៤០) ។

ធាតុ= (ម.ថ.ធាត) ន. ដី, ទឹក, ភ្លើង, ខ្យល់, អាកាសហៅថាធាតុ; អាការក្នុងខ្លួន ដូចយ៉ាងសក់, ធ្មេញ, ឈាមជាដើមហៅថាធាតុ ។

បុគ្គល= (ម.ថ. បុក-គល់) (ក្នុងវេទះជា គុ.) ដែលគួរខ្ពឹមរអើម, ដែលជារូបសាកសពស្រស់នៃមនុស្ស ។

ពិសោធ= កិ. សាក, ល្បង, លមើល (essayer) ។

ស្លេស្ម= (ម.ថ. ស្លែស) ន. ទឹករំអិលពារបុរាប់ដែលចេញមកតាមបំពង់ក ។

សម្ផស្ស= (ម.ថ. សំផស់) ន. ការប៉ះពាល់ត្រូវព្រមនៃ

អាយតនៈ (sensation) ។

សម្បជញ្ញៈ= (ម.ថ. ស័មប៉ៈជ័ញ ញៈ) ន. សេចក្ដីដឹងខ្លួន,

ការត្រិះរិះរំពឹងដឹងខ្លួនជាដរាប (conscience) ។

ប្រតិកម្ម= (ម.ថ. ប្រ-តិកាំ) ន. ដំណើរដែលតភ្ជាប់គ្នា

(circulation) ។

វិញ្ញាណ= (ម.ថ. វិញ-ញាន) ន. ធម្មជាតិជាគ្រឿងដឹងនូវ

អារម្មណ៍យ៉ាងច្បាស់ ។

សង្ខារ= (ម.ថ. សង់ខា) ន. គ្រឿងតាក់តែង, សពាង្គរាងកាយ

សុគស្នាញ - គុ. ដែលស្នាញចាក់ស្រែះ ។

តណ្ហា= (ម.ថ. តន់ហា) ន. បំណង, សេចក្ដីប្រាថ្នា,

(passion) ។

និន្ទាការ= (ម.ថ. និន-ទាកា) ន. ការលើកសរសើរ ។

## ៧. អត្ថាភិវុឌ្ឍ

"វង់" មានប្រើតែមួយយ៉ាងប៉ុណ្ណោះ ប៉ុន្តែមានសេចក្ដីផ្សេងគ្នាយ៉ាងនេះ ៗ

វង់= ក. ធ្វើឲ្យជារង្វង់: វង់ក្អែកក្អាក, ឈរដំវង់ ៗ

វង់= ខ. មណ្ឌលមូល: វង់ចិញ្ចៀន, ក្ងើងមួយវង់, ចិញ្ចៀនមួយវង់, វង់ព្រះអាទិត្យ, វង់ក្របក ៗ

វង់= ខ. ឈ្មោះល្បែងស៊ីសងមួយយ៉ាង: ក្មេងលេងគប់វង់ ៗ

វង្ស= (ម.ថ.វង់) ខ. ពូជអម្បូរ: ព្រះរាជវង្ស ៗ

# ៣៣. កម្មនិងបដិសន្ធិជាថ្មី

ជនអ្នកកាន់ពុទ្ធសាសនាយល់ឃើញថា សត្វទាំងអស់នៅលើផែនដី សុទ្ធតែត្រូវប្រតិបត្តិតាមច្បាប់មួយ ដែលមិនអាចលក់ប្ដូរទៅអ្នកណាមួយនិងមិនអាចសាបសូន្យ ឬក៏ប្រែប្រួលទៅបាន ។ ព្រះពុទ្ធត្រាស់ថា: «បើវត្ថុនេះកើតមាន គឺកើតមានឡើងពីវត្ថុនោះ; ព្រោះតែមានវត្ថុនោះ ទើបមានវត្ថុនេះ, បើវត្ថុនោះមិនមាន វត្ថុនេះក៏មិនអាចកើតមានដែរ, ព្រោះតែវត្ថុនោះវិនាស ទើបវត្ថុនេះរលាយទៅដែរ» ។ នេះជាធម៌មួយនិយាយអំពីកម្ម ។ សៀវភៅធម៌ខាងសាសនាកាតូលិក មានសរសេរថា «បើអ្នកដាំដំណាំអ្វី, អ្នកនឹងច្រូតយកផលដំណាំនោះ» ។ វិទ្យាសាស្ត្រគង់អធិប្បាយថា ហេតុផលស្មើនឹងលទ្ធផល, ឯលទ្ធផលផ្ទុយពីហេតុផលទៅវិញ» ។ អំពើណាមួយរបស់មនុស្សទោះល្អក្តីអាក្រក់ក្តី អាចនឹងឲ្យផលក្នុងបច្ចុប្បន្ន និងអនាគតមិនខាន ។ ឥតមាននរណាមួយ

គេបន្តពីផលកម្មដែលខ្លួនបានធ្វើឡើយ ៗ និយាយតាមបរិយាសាស្ត្រ, ផលកម្មនេះបង្ហាញឲ្យឃើញការទទួលយកនូវបុណ្យនិងបាប តាមអំពើល្អនិងអាក្រក់ដែលយើងបានធ្វើទុកមក ៗ

### គ. ពាក្យពន្យល់

កម្ម = (ម. ថ. កាំ) ន. អំពើ; កិច្ចការ (action) ៗ

បដិសន្ធិ = (ម. ថ. ប៉.ដិសន់ធិ) ន. ដំណកំណើតសត្វ ៗ

ប្រតិបត្តិ = (ម. ថ. ប្រតិបាត់) កិ. ប្រព្រឹត្ត; ធ្វើតាម ៗ

សោបស្មូន្យ = គុ. សោះសូន្យ ៗ

វិនាស = កិ. អន្តរាយ; បាត់បង់; រលាយ ៗ

វិទ្យាសាស្ត្រ = (ថ.ម. វិតទ្យា-សាស) ន. វិជ្ជាពួកមួយដែលគេរកឃើញដោយការពិសោធ មានការពិសោធជាគោលដើម (science) ៗ

លទ្ធផល = (ម. ព. ក្នុងអត្ថបទលេខ ២២) ។

បច្ចុប្បន្ន = (ម. ថ. ប៉ុច-ចុប-បន់) ន. ពេលដែលតាំង

នៅក្នុងកាលថ្មី ។

បរិយាសាស្ត្រ = (ម. ថ. បៈរ៉ិយ៉ាសាស) ន. ក្បួនខ្នាត

ដែលសំដែងអំពីឫកពាមារយាទ (moralie) ។

១. អក្ខរាវិរុទ្ធ

## ព្រួស-ព្រោះ

ព្រួស = កិ. បញ្ចេញទឹកឬទឹកមាត់ឲ្យខ្ចាយដោយកំ-ឡាំងខ្យល់ : ព្រួសទឹក, គ្រូស្ដោះព្រួស ។

ព្រោះ = កិ. បាចគ្រាប់ពូជដើម្បីឲ្យដុះ (ព្រោះស្រូវ, ព្រោះគ្រាប់ថ្នាំ) ។

ព្រោះ = គ. និ. ហេតុ, ដ្បិត (រៀនពុំចេះព្រោះខ្ជិល) ។

## ព្រុស - ព្រួស

ព្រុស = កិ. (ម. កុស ឬ កុស្ស) ប្រឹងដកកន្ត្រក: ឆ្កែ ព្រុសពុំដែលខាំ ។

ព្រួស = ១. សូរឮដោយដួល, ធ្លាយ, ធ្លាក់, ទធាក់ (ដួលព្រួស, ធ្លាក់ព្រួស, ទធាក់ព្រួស ៗ) ។

ព្រួស = ២. ឈ្មោះឈើព្រៃមួយយ៉ាង (ផ្លែព្រួស) ។

សង្កេត. គេពុំដែលសរសេរ ព្រុះ (ព + ្រ + ុ + ះ) យ៉ាងនេះឡើយ ។

# ៣៥. និព្វាន

អ្វីជាទីដៅរបស់ពុទ្ធសាសនា ? អ្នកកាន់ពុទ្ធសាសនាបានឆ្លើយថាព្រះនិព្វាន ។ ឆ្លើយដូច្នោះពិតជាត្រូវតាមអត្ថជាពិតប្រាកដ ។ ទីបំផុតរបស់ពុទ្ធសាសនាគឺ "ព្រះនិព្វាន" ព្រោះជាកន្លែងរំលត់ទុក្ខ ជាកន្លែងទទេ និងជាកន្លែងបញ្ឈប់ដំណើររបស់ជាតិ ។ ពូជនៃកិលេសតណ្ហាតូច ៗ មានអនុស័យកិលេសនឹងកិលេសធំៗ ទាំងឡាយមានរាគៈទោសៈមោហៈជាដើម ដែលនាំឲ្យបន្តនូវជាតិ ជរាព្យាធិនឹងមរណៈក្នុងវាលវដ្តសំសារនោះ ឥតមានសេសសល់ក្នុងព្រះនិព្វាននោះទេ គឺរលត់សូន្យសោះរកនិមិត្តគ្មាន ។ និយាយយ៉ាងខ្លីមកថាព្រះនិព្វានជាកន្លែងបញ្ឈប់កំណើតថ្មីរបស់សត្វ ឥតមានជាតិជរាព្យាធិនឹងមរណៈ ឡើយ មានតែបរមសុខតែមួយប៉ុណ្ណោះ ។ ព្រះនិព្វានជាស្ថានសប្បាយនៃព្រះអរិយបុគ្គលទាំងឡាយដែលផុតវិស័យរបស់បុថុជ្ជនដឹងបាន ។

## ក. ពាក្យពន្យល់

និព្វាន=(ម.ថ. និប-ពាន) ន. ព្រះធម៌រលត់កិលេស, រំលត់បញ្ចក្ខន្ធ គឺលោកុត្តរធម៌ទី ៩ ដែលកើតអំពីលោកុត្តរធម៌៨ខាងដើម (មគ្គ៤, ផល៤) ។

ពុទ្ធសាសនា=(ម.ព. ក្នុងអត្ថបទលេខ ៣១) ។

អត្ថ=(ម.ថ. អ័ត) ន. សេចក្ដី, ពាក្យប្រែស្រាយ ។

ប្រាកដ=(ម.ព. ក្នុងអត្ថបទលេខ ១១) ។

ជាតិ=(ម.ថ. ជាតិ) ន. កំណើត ។

ពូជ= ន. ដំណជាតិកំណើត ។

កិលេស= ន. សេចក្ដីសៅហ្មងចិត្ត ។

អនុស័យកិលេស= ន. កិលេសតូចតាច, កិលេសបន្ទាប់បន្សំ ។

រាគ:= ន. ដម្រេក, សេចក្ដីត្រេកត្រអាលចំពោះកាម ។

ទោស:= ន. សេចក្ដីប្រទូស្ដ, កំហឹង, កំហុស ។

មោហ:= ន. អវិជ្ជា, សេចក្ដីវង្វេង ។

វាលវដ្ដសង្សារ= (ម.ថ.- វ៉ត់-ដ:សង់សា) ន. លោកដែលសត្វតែងតែអន្ទោលវិលកើតវិលស្លាប់ ។

និមិត្ត= (ម.ថ. -មិត) ន. ដើមហេតុ, គោលចារឹក, គ្រឿងសំគាល់, លក្ខណ: ។

បរមសុខ= (ម.ថ. ប-រ៉ុម-) ន. សុខដ៏ក្រៃលែង, សេចក្ដីសុខដ៏ល្អិតសុខុម ។

អរិយបុគ្គល= (ម.ថ.- អ:រ៉ិយ:បុក.គល់) ន. បុគ្គល ៨ ពួក រាប់តាំងពីអ្នកដែលបានសម្រេចសោតាបត្តិមគ្គ រៀងទៅដល់អ្នកដែលបានសម្រេចអរហត្តផល ។

វិស័យ= (ម.ថ.វិ៉ស) ន. គំនិត, អារម្មណ៍, សេចក្ដីដឹង ។

1

បុថុជ្ជន= (ម.ថ.ប៉ុថុប-ជន់) ន. ជនដែលមិនទាន់សម្រេច

គុណវិសេសណាមួយ, ជនសាមញ្ញធម្មតា ។

១. អក្ខរាវិរុទ្ធ

និញ្ចាន= សរសេរជា, ន + ិ + ញ + ្ច + ា + ន យ៉ាងនេះតែម្យ៉ាង, គេមិនដែលសរសេរជានិញ្ចាន្ត យ៉ាងនេះឡើយ ។

ទទេ-ទំនេរ

ទទេ= គេសរសេរគ្មានវបុងឡើយ ។ ចំណែកខាង

ទំនេរ= ដែលមានសេចក្ដីស្រដៀងនឹងទទេដែរ, គេសរសេរមានវបុង ។

បន្ត មកពីពាក្យ ត, គេសរសេរគ្មានវបុងឡើយ ។

ពាក្យដែលត្រូវសង្កេត:

## ត- ដំណ- បន្ត

គេសរសេរគ្មានរូបុនទាំងអស់ ។

## សេស-សេះ

សេស= (ម. ថ. សេស) គុ. ដែលសល់: អាហារសេសសល់, របស់សេសសល់ ។

សេះ= ន. បសុសត្វបតុប្បាទ (សេះជាសត្វខ្លាំងហួសមាឌ ទាំងបុំទធន់ទ្រាំក្តៅទីទ្រជាក់ផង) ។

សេះ= ន. ឈ្មោះក្តាមសមុទ្រមួយយ៉ាង (គេទៅទទួលទានក្តាមសេះនៅកំពត) ។

## ៣៤. អធ្យាស្រ័យក្នុងព្រះពុទ្ធសាសនា

ព្រះសម្មាសម្ពុទ្ធទ្រង់ពន្យល់ពុទ្ធបរិស័ទឲ្យដឹងច្បាស់នូវដើមហេតុដែលមានកស្តុតាងពិតប្រាកដ ហើយទ្រង់ដឹកនាំសត្វឲ្យប្រតិបត្តិតាមដោយវិធីទេសនា និងចរិយាសាស្ត្រ ។

ទ្រង់មានអធ្យាស្រ័យទោរទន់អាណិតសត្វលោកដែលកំពុងសោកក្ដុយជាប់ជំពាក់ក្នុងបណ្ដាញគឺតណ្ហា ជាហេតុ ជាបច្ច័យឲ្យមានជាតិជរាព្យាធិនិងមរណៈ រកទីបំផុតគ្មាន, ចង់ចម្លងឲ្យផុតពីអន្លង់ទុក្ខ ទើបទ្រង់សំដែងធម៌វិន័យឥតធុញទ្រាន់ដើម្បីឲ្យសត្វប្រតិបត្តិធ្វើតាម ។ តែការទូន្មាននោះ ទ្រង់ប្រើតែការណែនាំពន្យល់ទាញហេតុផលមកបង្ហាញ ឲ្យបរិស័ទឃើញឬចូលចិត្តបានប៉ុណ្ណោះ មិនមែនប្រើអំណាចផ្ដាច់ការតាមកំឡាំងនោះឡើយ ។ បើតាមបុណ្យ, ឫទ្ធិអំណាចនិងកំឡាំងកាយឬ កំឡាំងចិត្តរបស់ព្រះអង្គ ឃើញថាប្រសើរជាងមនុស្សនិងទេវតាមារព្រហ្មទៅទៀត, តែព្រះអង្គមានមធ្យា-

បាយល្អ បេះដឹកនាំសត្វឲ្យវង្វេងផុត ពីធម៌ជាគ្រឿងរាំងនឹងធម៌ដែលនាំសត្វឲ្យយឺតយូរ ដោយការពន្យល់បង្ហាញផ្លូវដោយព្រះទ័យដ៏ទោរទន់ ឥតប្រើអាការដ៏ឃោរឃៅជាហេតុនាំឲ្យខូចទឹកចិត្តសេរីរបស់មនុស្សលោកឡើយ ។

## គ. ពាក្យពន្យល់

អធ្យាស្រ័យ= (ម.ព. កង់អត្ថបទលេខ១៧) ។

ពុទ្ធបរិស័ទ= (ម.ព. កង់អត្ថបទលេខ៣១) ។

ភស្តុតាង= (ម.ព. កង់អត្ថបទលេខ១១) ។

ប្រតិបត្តិ= (ម.ព. កង់អត្ថបទលេខ៣៣) ។

បរិយាសាស្ត្រ= (ម.ព. កង់អត្ថបទលេខ៣៣) ។

បណ្ដាញ= ន. អ្វីៗដែលមានក្រឡាប្រទាក់ជាសំណាញ់ ។

តណ្ហា= (ម.ព. កង់អត្ថបទលេខ៣២) ។

បច្ច័យ= (ម.ព. កង់អត្ថបទលេខ៧) ។

ជរា= ន. សេចក្ដីគ្រាំគ្រា, សេចក្ដីចាស់ទ្រុឌទ្រោម ។

ព្យាធិ= ន. ជម្ងឺ, រោគ, អាពាធ ។

មរណៈ ន. សេចក្ដីស្លាប់ ។

ទេវតា= ន. អមនុស្សដែលជាទិព្យ ។

មារ= ន. ឈ្មោះទេវបុត្រដែលជាសត្រូវចំពោះព្រះពុទ្ធ ។

ព្រហ្ម=(ម.ថ.ព្រំ) ន. ទេវតាដែលកើតនៅព្រហ្មលោក

ដោយអំណាចផលនៃឈានចិត្ត ។

មធ្យោបាយ=(ម.ព. ក្នុងអត្ថបទលេខ១៦៦) ។

ឃោរឃៅ= គុ. ហៅហាន; ក្លាខ្លាំងឥតមានមេត្តាប្រណី ។

ទឹកចិត្តសេរី= ចិត្តដែលតាំងនៅលើដំហរសេរីភាព ។

១. អគ្គារក្ខ

អធ្យាស្រ័យ= គប្បីសរសេរជា «អ+ធ+្យ+ា

+ស+ ្រ + ័ +យ,, យ៉ាងនេះតែម្យ៉ាង, គេមិនដែលសរសេរជា: អាស្រ្ស័យ យ៉ាងនេះឡើយ ។

## កម្ម-កាំ

កម្ម= (ម.ថ. កាំ) ន. អំពើ(បុគ្គលត្រូវមានកម្មជារបស់ខ្លួន; ខ្ញុំធ្វើនូវកម្មណាដែលល្អ) ។

កាំ= ន. ឈើៗ ដែលរៀបជាជាន់សម្រាប់រង (កាំជណ្ដើរ, កាំរទេះ) ។

បរិស័ទ= សរសេរបានពីរយ៉ាងគឺ:

ប+រ+ ិ +ស+ ័ +ទ= បរិស័ទ នេះម្យ៉ាង ។

ប+រ+ ិ +ស+ទ+ ្យ= បរិសទ្យ នេះម្យ៉ាង ។

## បិត-បិត្ត

បិត= កិ. កាត់ជាបំណិត (ចុងកៅបិតបន្ទៃ) ។

បិត្ត= កិ. បិតសម្រួច (សិស្សបិតខ្មៅដៃ) ។

បិត្ត = ន. ធម្មជាតសម្រាប់សន្សំអារម្មណ៍ (លោកគ្រូនេះមានបិត្តល្អណាស់) ។

## ៣៦. ជាតិ

ប្រជុំពលរដ្ឋ របស់ប្រទេសដែលនៅរួបរួមគ្នា, នៅក្រោមការគ្រប់គ្រងជាមួយគ្នា, រស់នៅក្នុងប្រទេសរួមគ្នា, មានជាតិពន្ធុដូចគ្នា និយាយភាសាដូចគ្នា, កាន់សាសនាត្រូវគ្នា មានប្រវត្តិការ កើតមកនិងទំនៀមទំលាប់ប្រពៃណីត្រូវគ្នា, ប្រតិបត្តិច្បាប់សម្រាប់រដ្ឋត្រូវគ្នា និងរស់នៅក្នុងលក្ខណៈជាពួកជាក្រុម ជាសង្គមដោយសេចក្ដីស្ម័គ្រចិត្តហៅថាជាតិ ៗ ជាតិមានគ្រឿងសំគាល់ប្រហែលគ្នានឹងរដ្ឋ តែជំទូលាយជាងរដ្ឋ គឺមានលក្ខណៈរបស់រដ្ឋនិងលក្ខណៈរបស់សញ្ជាតិរួមគ្នា ៗ

ជាតិជាគ្រឿងសំគាល់ស្ដែង ឲ្យបុគ្គលដឹងថាខ្លួនគេជាសមាជិករបស់រដ្ឋណា ជាពលរដ្ឋរបស់ប្រទេសណា ៗ បើមនុស្សគ្មានជាតិជាគ្រឿងសំគាល់ទេ គេមិនអាចដឹងបានថាមនុស្សនោះជាជាតិអ្វី រដ្ឋក៏មិនអាចទទួលស្គាល់នូវជននោះថាជាពលរដ្ឋរបស់គេឡើយ ៗ ដូចនេះ ជាតិជាសារៈសំខាន់បំផុត សម្រាប់បញ្ជាក់នូវតួបុគ្គលឲ្យដឹងថាជាពលរដ្ឋរបស់

ប្រទេសនេះឬប្រទេសនោះ ។

ជាតិប្រៀបដូចជាវិញ្ញាណរបស់រដ្ឋ ព្រោះជាគ្រឿងសែ្តងឲ្យដឹងថាបុគ្គលណាខ្លះដែលជាពលរដ្ឋរបស់រដ្ឋ ទើងអាចបង្គាប់នូវបុគ្គលទុកនឹងរដ្ឋយ៉ាងជាប់បាន ។ បើមានតែរដ្ឋមិនមានជាតិ ប្រៀបដូចជាបុគ្គលដែលមានតែកាយឥតវិញ្ញាណ ។

ក. ពាក្យពន្យល់ (explications)

ជាតិ= (ម.ថ. ជាត) ន. កំណើត (race) ។

ពលរដ្ឋ=(ម.ថ.ពល់រ៉ត់)ន.ជនអ្នករស់នៅក្នុងរដ្ឋ(citoyen)។

ពង្ស= (ម.ថ. ពាន់) ន. ពូជពង្ស, សែស្រឡាយ(lignée)។

ប្រវត្តិការ= (ម.ថ. ប្រ-វាត់-ត-កា) ន. ការប្រព្រឹត្តទៅ, ការរស់នៅ ។

សង្គម= (ម.ថ. សង់-គំ) ន. ក្រុម, ការជួបជុំគ្នា, ការគេប់

រកគ្នា ។

សញ្ជាតិ= (ម.ថ.សាញ់-ជាតិ) ន. ការកើតឯង, ការកើត តាមធម្មតា ។

សមាជិក= (ម.ថ.សៈ-ម៉ា-ជិក) ន. អ្នកដែលមានអំណាច ត្រូវចូលទៅកាន់ទីប្រជុំបាន, អ្នកចូលក្នុងសមាគម (ស. សមាជិកា) ។

សារៈ= (ម ថ.សា-រ៉ះ) ន. ខ្លឹម, សេចក្ដីខ្ជាប់ខ្ជួន, លក្ខបាន, គោលចារឹក ។

វិញ្ញាណ= (ម.ថ.វិញ-ញ៉ា-ណ)ន. ធម្មជាតដឹងអារម្មណ៍ ច្បាស់ៗ

១. អក្ខរាវិរុទ្ធ (orthographe)

ពលរដ្ឋ= អានថា ពល់-រ៉ត់ ពីរោះជាងអានថា ពៈលៈរ៉ត់ ។

គ្រប់ ច្រើនអានថាគ្រុប តែត្រូវសរសេរថា គ្រប់ យ៉ាងនេះហូត

ដូចពាក្យថា

គ្រប់គ្រង = គ្រួតត្រា, ឃុំគ្រង ។

សព្វគ្រប់ = គ្រប់ទាំងអស់, គ្មានសល់ ។

បង្គ្រប់ = ធ្វើឲ្យគ្រប់ល្មម ។

វៀរលែងតែ

សង្គ្រប ត្រូវសរសេរ ស្រៈ វិញ

ឧទា. គ្នា សង្គ្រប កណ្ដុរ ។

ប្រពៃណី អានថា ប្រ-ពៃ-នី តែត្រូវសរសេរជាណី ។

ពាក្យដែលមាន ណី ខាងចុង ហើយត្រូវអានថា នី ៖

ចិន្តាមណី

កែវមណី

បវេណី

គណេស៍

។ល។

# ៣៧. សាសនា

កាលសម័យបុរាណ ចាប់តាំងពីមានជំនុំជនប្រភេទមួយ ដែលនាំគ្នាប្រកាន់ពួកបក្សឡើងនោះ កិច្ចការរបស់មនុស្ស កាលជំនុំជន ស្ទើរតែគ្រប់បែបគ្រប់យ៉ាង សុទ្ធតែមានគតិ ទិដ្ឋិ លទ្ធិនៃជំនឿប្រកបចូលទៅកាលផ្លូវចិត្ត នៃមនុស្សទាំងឡាយ នោះជាដរាប ៗ ជាកិច្ចការកាលស្រុកភូមិក្តីឬក្រៅស្រុកភូមិក្តី ឲ្យតែកិច្ចការនោះ ជាកិច្ចការដែលទាក់ជាប់ដោយសេចក្តីនឹក គិតខាងផ្លូវចិត្ត ហៅថា គតិទិដ្ឋិលទ្ធិទាំងអស់ ៗ ឧបនិស្ស័យ ចិត្តដើម ដែលបញ្ជាក់អាកប្បកិរិយាល្អអាក្រក់នៃជនម្នាក់ៗក្តី ជំនឿភ័យខ្លាចក្តី សឲ្យឃើញថាជាផលនៃគតិទិដ្ឋិលទ្ធិរបស់ ជនណាម្នាក់ដែលផ្តើមបង្កើតឡើង ៗ គតិទិដ្ឋិលទ្ធិនេះឯង ហើយដែលហៅថា "សាសនា" ៗ សាសនាអាចដឹកទឹក ចិត្តមនុស្សឲ្យប្រកាន់ជឿមាំកាលសរណវត្ថុ គ្រប់ៗសាសនា ៗ មនុស្សសម័យនោះប្រកាន់ថាត្រូវធ្វើពិធីផ្សេងៗ តាមគតិឬលទ្ធិ

នោះទើបនាំមកនូវសេចក្ដីសុខចំរើន បានទទួលផលល្អមិន មានសេចក្ដីវិនាសអន្តរាយ ។ គតិនិយមលទ្ធិនោះ កន្លងមកប្បន សម័យគេហៅថា «លទ្ធិសេយ្យសាស្ត្រ» ។ គតិនិយមលទ្ធិនេះ មានច្រើនយ៉ាងផ្សេងៗ គ្នា ។ គេនាំគ្នាជ្រះថ្លាតាមតែអ្នកដឹក នាំឬអ្នកកសាងលទ្ធិនោះ ។ ខ្វះតាំងឬសន្មតនូវវត្ថុណាមួយ ឡើងជាទេវតាដ៏ស័ក្ដិសិទ្ធិទ្រទ្រង់នូវឥទ្ធិឫទ្ធិផ្សេង ៗ មានអំ-ណាចធំបំផុតលើមនុស្សគ្រប់គ្នា ។ កន្លែពេលតមកទើបមានអ្នក-ប្រាជ្ញខាងផ្លូវសាសនាពិតៗ រៀបចំតាំងគោលបារកសាសនា ឡើងផ្សេងៗ ជាច្រើន ដែលជាសាសនាពិតប្រាកដដូចជា ពុទ្ធសាសនា គ្រិស្ដសាសនានិងឥស្លាមសាសនាជាដើម ។

### ឝ. ពាក្យពន្យល់

សាសនា= (ម.ថ. សា-ស:នា) ពាក្យបណ្ដាំ, ពាក្យប្រៀន ប្រដៅ, លទ្ធិ (Religion) ។

សម័យ= (ម. ថ. ស: ម៉ៃ) ន. កាល, ពេលឬវេលា,

ទុកាស, គ្រា ។

បុរាណ= (ម. ថ. បុ-រ៉ាណា) គុ. ចាស់, ដែលមានយូរ

ហើយ, ដែលកើតមានមុន ។

ពុំដុំ= ន. ទីប្រជុំជន, ពួក, ប្រជុំ ។

ប្រភេទ= ន. ចំណែក, ប៉ែក, ខ្សែ ។

បក្ស= (ម. ថ. ប៉ុក) ន. ចំណែក, ប៉ែក, ពួក, បន ។

គតិ= (ម.ថ. គៈតិ) ន. ដំណើរ, បែប, យ៉ាង, គំនិត ។

លទ្ធិ= (ម. ថ. ល័ុត-ធិ) ការឃើញ, សេចក្ដីយល់

ឃើញ, ជំនឿ ។

ឧបនិស្ស័យ= (ម. ថ. អ៊ុប៉ៈនិសសៃ) ន. កុសលធម៌

ដែលដេកផ្អាស្រ័យនៅក្នុងខន្ធសន្ដាន គឺកុសលដែល

បានកសាងសន្សំអប់រំទុកមក, សំណាង, កញ្ចព្រេងវា-

សនា ។

អាកប្បកិរិយា= (ម. ថ. អាក័ប-ប៉. កិរិយ៉ា) ន. ដំណើរបែបភាពនៃកាយ, ដំណើរឬលំនាំនៃកាយឬនៃបុគ្គល ។

ឆ្ងល់= ន. (ក្ដីនេះ) កំសួល, ការបញ្ឈាក់ ។

សរណត្រ័យ (ម. ថ. ស: រ: ណា:-) របស់សម្រាប់ទីពឹង របស់សម្រាប់ពឹងផ្អែក, របស់សម្រាប់អាង ។

លទ្ធិសៀយ្យសាស្ត្រ ឬ – សៃយសាស្ត្រ ឬ – ឈាស័ន = (ម.ថ.– សៃ-យ:សាស) ន. ការយល់ឃើញក្រៅព្រះពុទ្ធសាសនា ។

ស័ក្តិសិទ្ធិ=(ម.ថ.ស័ក–សិត) គុ. ដែលមានអំណាចឬដែលអាចឲ្យសម្រេចប្រយោជន៍បាន, ដែលខ្លាំងពូកែ, ដែលវិសេសវិសាល ។

ឥទ្ធិឫទ្ធិ=(ម.ថ. ឥតធិ៊ត) ន. អានុភាពក្រៃលែងជាងធម្មតា, អំណាចដ៏ស័ក្តិសិទ្ធិឬជាក់ស្តែង, ឫទ្ធិដ៏អស្ចារ្យ ។

១. អក្ខរាវិរុទ្ធ

ជុំគុំ ស្រៈសេរជា ជុ + ំ និង គុ + ំ មិនត្រូវ ស្រៈសេរជា ជុំគុំ យ៉ាងនេះឡើយ ។

សង្កេត. ពាក្យពីរព្យាង្គឬច្រើនព្យាង្គ ដែលមានពាក្យ ជំ នៅខាងមុខ សុទ្ធតែស្រៈសេរជាមួយ

ជំ នេះទាំងអស់ដូចជា: ជំងឺ, ជំទប់, ជំទាវ ជាដើម ។ វៀរលែងតែពាក្យបីម៉ាត់ចេញគឺ:

ជុំ= កិ. ឬ កិ. វិ. មូលគ្នា ។

ជុំ= ន. ដំណើរវង់វិលជួបមកកន្លែងដដែលវិញ ឧទា. ដើរប្រទក្សិណព្រះវិហារ៣ជុំ ។

ជុំកន្ទង់= ន. ឈ្មោះល័ខមួយយ៉ាងហៅថាល័ខជុំកន្ទង់

ប៉ុន្តែកាលបើពាក្យជុំនេះ នៅចុងពាក្យវិញច្រើនតែស្រៈសេរជាមួយនឹងជុំ ដូចពាក្យថា: ជួបជុំ, ប្រជុំជាដើម ។

# ៣៨. ព្រះមហាក្សត្រ

អរិយជនជាន់ខ្ពស់បំផុតរបស់ប្រទេសហៅថា "ព្រះមហាក្សត្រ" ។ ព្រះមហាក្សត្រស្ថិតនៅលើព្រះរាជបល្ល័ង្កផុតពីសង្គមនយោបាយ ពុំលាយឡំនឹងរាស្ត្រប្រជាឡើយ ។ ប្រជាជនក្នុងប្រទេសដែលមានព្រះមហាក្សត្រគ្រប់គ្រងតែងបានកក់ក្ដៅអប់ឧណ្ហដោយសារព្រះរាជបារមីរបស់ព្រះអង្គ ។ ព្រះរាជាទុកដូចជាមាតាបិតាបង្កើតផ្ទាល់របស់ប្រជារាស្ត្រព្រោះព្រះអង្គទ្រង់មានទឹកព្រះទ័យប្រកបដោយមេត្តាព្រហ្មវិហារធម៌ ។ ពិសេសពីនោះ ព្រះអង្គទ្រង់មានទសពិធរាជធម៌ជាលំអព្រះវរកាយរបស់ព្រះអង្គ ចំពោះរាស្ត្រទៀត ។

ទសពិធរាជធម៌នោះគឺ ការប្រទាននូវអំណោយដ៏ស្មោះ ១, រក្សាសីល ១, បរិច្ចាគព្រះរាជទ្រព្យសម្រាប់ប្រទេស ១, ទៀងត្រង់ចំពោះរាស្ត្រ ១, អធ្យាស្រ័យទន់ភ្លន់ ១, កំចាត់បាបពីសន្ដាន ១, ពុំមានក្ដីក្រោធ ១, មិនបៀតបៀនអ្នកដទៃ ១,

ខ្ទី ១ និងគម្រប់១០គឺការមិនគំរើកព្រះទ័យ ដោយសេចក្ដីសរសើរនិងនិន្ទា ។

ប្រជារាស្ត្រគ្រប់ជាន់ថ្នាក់ គប្បីគោរពព្រះមហាក្សត្ររបស់ខ្លួនឲ្យដូចជាសរណវត្ថុ ត្រូវមានកតញ្ញូភាពចំពោះព្រះអង្គ តាមដង្ហែ ជាសេនាបំរើគ្រប់គោលការណ៍នានា ។

គ. ពាក្យពន្យល់

មហាក្សត្រ= (ម.ថ. មហាក្សត្រ) ន. ស្ដេចធំ, ព្រះរាជាដ៏ប្រសើរ ។

អរិយជន = (ម.ថ. អ-រិ-យៈជន់) ន. ជនដ៏ប្រសើរ, ជនដ៏ខ្ពង់ខ្ពស់ ។

រាជបល្ល័ង្ក= (ម.ថ.–បុល្ល័ង) ន. ព្រះទីនសម្រាប់ព្រះរាជាទ្រង់គង់ពេនព្រះបាទ ។

នយោបាយ= (ម.ថ.នៈ–) ន. ឧបាយជាគ្រឿងណែនាំ

(politique) ។

រាស្ត្រប្រជា=(ម.ថ.រាស--ប្រជា) ន. ពួករាស្ត្រ, ប្រជាជន ។

ប្រជាជន= (ម.ថ.-ជន់) ន. ពពួកនៃជន ។

អប់ឧណ្ហា= (ម.ថ.អប់-អុន) គុ. កក់ក្ដៅ (réchauffé)

រាជបារមី= (ម.ថ.រាច-ប៉ារ:មី) ន. គុណជាតិដ៏ល្អរបស់
ព្រះរាជា, អំណាចដ៏ខ្ពង់ខ្ពស់របស់ព្រះរាជា ។

ព្រហ្មវិហារ= (ម.ថ.ព្រំម:-វិហា) ន. ធម៌ជាលំនៅនៃចិត្ត

ទសពិធរាជធម៌= (ម.ថ.ទសស:ពិត-រាជ:ធ័រ) ន. ធម៌
សម្រាប់ព្រះរាជា ១០ យ៉ាង ។

ព្រះវរកាយ= (ម.ថ.-វរកាយ) ន. ខ្លួនព្រះរាជា ។

បរិច្ចាគ= (ម.ថ.បរិច-ចាក) កិ. លះបង់, ចែកចាយ ។

ខន្តី= (ម.ថ.ខ័ន-តី) ន. ការអត់ធ្មត់, អំណត់ ។

កតញ្ញុភាព=(ម.ថ.ក:តញ-ញុ-) ន. ភាពជាអ្នកដឹងគុណ ។

១. អក្ខរាវិរុទ្ធ

បល្ល័ង្ក អានថា បាល់-ឡាំង, ចូរសរសេរអក្សរមួយ មួងយ៉ាងនេះ ប + ល + ្ល + ័ + ង + ្ក ៗ

ឧណ្ហ អានថា អ៊ុន ត្រូវសរសេរជា ឧ + ណ + ្ហ

ឧទា. ក្ដៅឧណ្ហ ៗ, ខ្ញុំឧណ្ហកន្ទិតចិត្តថាទៀងពីបាន ៗ

លំអ=អ្នកសរសេរភាគច្រើន, ច្រើនសរសេរមានរ ចុង តែគប្បីសរសេរឲ្យឆាយចាំយ៉ាងនេះ, លំអ មកពីពាក្យថា លម្អ គុ., ទៅជាន. ជា លំអ ៗ ដូចនេះគប្បីសរសេរគ្មានរ ចុង ៗ

សីល= អានថា សិល តែសរសេរជា ស + ី + ល

ឧទា. ព្រះសង្ឃមានសីលជាគ្រឿងលំអ ៗ

បរិច្ចាគ=ត្រូវសរសេរជា: ប + រ + ិ + ច + ្ច + ា + គ ឧទា. ឧបាសកបរិច្ចាគនូវធនធានដើម្បីធ្វើបុណ្យ ៗ

អធ្យាស្រ័យ= ត្រូវសរសេរទាំង អ + ធ្យា + ស្រ័យ កុំ

សរសេរជា អា + ធ្យា + ស្រ័យ យ៉ាងនេះទៀយ ។

សរសើរ=សរសេរជា ស + រ + សើ + រ ។

# ៣៩. ពលរដ្ឋ

ជនណាដែលស្ម័គ្រចិត្តដោយស្មោះចូលជាជាតិនេះឬជាតិនោះ ហៅថាពលរដ្ឋ ។ ពលរដ្ឋនីមួយ ៗ មិនមែនចាំបាច់តែនៅអាស្រ័យក្នុងរដ្ឋជាមួយគ្នាជាដរាបនោះទេ ។ ពលរដ្ឋរបស់ជាតិអាចនឹងអាទេសជាតិរបស់ខ្លួន ឲ្យទៅជាពលរដ្ឋរបស់ជាតិដទៃបានតាមសេចក្ដីស្ម័គ្រ ។ វេលាដែលបានប្ដូរជាតិរួចហើយ ជននោះក៏ក្លាយទៅជាពលរដ្ឋរបស់ជាតិដទៃយ៉ាងជ្រះស្រឡះ ។ មានសញ្ជាតិថ្មីប្រើជំនួសសញ្ជាតិចាស់របស់ខ្លួន ។ រដ្ឋក៏ត្រូវទទួលនូវកំហាតមួយយ៉ាងធំ ព្រោះត្រូវកាត់បញ្ជីបម្រើនគ្រួសារអស់មួយ ក្នុងពេលនោះ ។

ពលរដ្ឋក្នុងរដ្ឋណាមួយ នាំគ្នាភៀសខ្លួនទៅប្រកបអាជីវកម្មក្នុងទីដទៃ ក្រៅពីរដ្ឋរបស់ខ្លួន ដូចជាដីដែលទើបនឹងស្វែងរកឃើញថ្មីឬដីត្រង់កន្លែង ដែលនៅមិនទាន់ចំរើនជាដើម តាំងខ្លួនជាអ្នកគ្រប់គ្រងផែនដីត្រង់ភាគនោះ មានរដ្ឋាភិបាល

របស់ខ្លួនដាច់ដោយឡែក មិនឡើងឬមិនរួមទៅ នឹងរដ្ឋដើមរបស់ខ្លួនឡើយ ហៅថា «ពលរដ្ឋអាកៀសខ្លួន» ។ រដ្ឋថ្មីដែលពលរដ្ឋអាកៀសនោះគ្រប់គ្រង ហៅថារដ្ឋអាកៀស ។

ក្នុងឋានៈនៃយើងជាពលរដ្ឋម្នាក់ យើងមិនត្រូវឲ្យប្រទេសខាតបង់នូវខ្លួនយើងដែលជាពលរដ្ឋល្អឡើយ ព្រោះថាពលរដ្ឋល្អប្រទេសចំរើន ។

## គ. ពាក្យពន្យល់

ស្ម័គ្រ = (ម.ថ. ស្វាក់) កិ. ពេញចិត្តចូលជាមួយ, ពេញចិត្តធ្វើពីខ្លួនឯង ។

អាទេស = កិ. ប្ដូរ, ផ្លាស់ប្រែ, ផ្លាស់ឲ្យប្លែកចាកភាពដើម ។

កំហាត = ន. ការខាតបង់ ។

អាកៀស = កិ. កៀសខ្លួនមិនឲ្យគេស្គាល់, គេចវៀះកៀស

១ន ។

អាជីវកម្ម= (ម.ថ. អា-ជី វៈក័ម) ន. របរសម្រាប់ចិញ្ចឹម

ជីវិត ។

ភាគ= ន. ចំណែក, ប៉ែក ។

រដ្ឋាភិបាល= (ម.ថ. រ័ត-ឋា ភិ-បាល) ន. អ្នកគ្រប់គ្រង

គេក្នុងប្រទេស (ដំណាងក្សត្រទ្រង់ពង្ស) ។

១. អត្ថាធិប្បាយ

ស្មុគ្រ= អានថាស្មុក, សរសេរជាៈ ស+ុ+្+

គ+្រ ។

រដ្ឋ= អានថារ័ត, សរសេរជា រ+ដ+្ឋ ។

ពាក្យដែលជាសទិសស័ព្ទនឹងពាក្យរដ្ឋគឺ ។

រ័ត្ន= ន. ត្បូងគ្រប់យ៉ាង, កែវ, ពេជ្រ ។

រដ្ឋ= ន. ដែន, ប្រទេស, ឧទា. ខ្ញុំនៅកូនរដ្ឋខ្មែរ ។

## ដ នឹង ដ៏

កាលបើពាក្យមានតាំងពីពីរព្យាង្គឡើងទៅ, គេត្រូវសរសេរនឹង ដ (គ្មានអស្តា) ។

ដដែល = និយាយដដែល ៗ ។

ដទៃ = អ្នកនោះមានចិត្តដទៃពីខ្ញុំ ។

ដរាប = ដរាបណាខ្ញុំឈប់រៀន ដរាបនោះទើបខ្ញុំចង់ធ្វើការ ។

ដឡុងដ្ឋដលង់ = អស់កាលដលង់ ខ្ញុំមិនដែលឃើញលោកគ្រូសោះ ។

## រឿរលែងតែ

ដ៏ហើយ = ប្រាសាទដ៏ហើយដោយថ្មសុទ្ធ១នេះចេញ ។

បំពោះ ដ៏ (មានអស្តា) នេះ ជា ន. មានសេចក្តីថា ដែលជា ឧទា. ជនដ៏ប្រសើរ ៗ ធម៌ដ៏បវរ ៗ ព្រះដ៏មានបុណ្យ ...

## ៤០ ប្រទេស

ផែនដីមួយកន្ទុង ដែលជាតិនីមួយ ៗ ប្រជុំគ្នានៅ ហៅថា: « ប្រទេស » វឌ្ឍនភាពនៃប្រទេសដែលអាចនឹងលូតលាស់ចំរុងចំរើនតទៅទៀតបាននោះ លុះណាតែមានការទ្រទ្រង់ប្រទេសជាមូលដ្ឋានដែរ លទ្ធិនិយមតាមនីតិន័យ អំពីកិច្ចការពារប្រទេស ប្រកាន់ថាប្រទេសណាដែលអាចនឹងទ្រទ្រង់ខ្លួន ឲ្យមានសិទ្ធិសេរីភាពនឹងអធិបតីភាពយ៉ាងបរិបូណ៌បានក៏ព្រោះតែប្រទេសនោះ មានការទ្រទ្រង់ជាមូលដ្ឋានពិតប្រាកដ ៗ ដូចនេះ ការធ្វើប្រទេសឲ្យនៅក្នុងការរឹងប៉ឹងនេះឯង ជាសិទ្ធិដែលប្រទេសទាំងឡាយត្រូវមានជាដំបូងបំផុត ។

ធម្មសាស្ត្រសាកលក្តី, ការគ្រប់គ្រងសាកលក្តី, ថែងថាការទ្រទ្រង់ប្រទេសឲ្យរឹងប៉ឹងនេះឯងជាអណ្តូងកើតនៃសិទ្ធិនានា ៗ ប្រទេសណាដែលបានតាំងខ្លួន នៅលើដំហររឹងប៉ឹងរួចហើយ ប្រទេសនោះតែងមានអំណាចច្រើនយ៉ាង ដូចជាមានអភ័យ-

ឯកសិទ្ធិសម្រាប់ជាតិ , សិទ្ធិរក្សខ្លួន , សិទ្ធិការពារខ្លួន , មូលនីតិនិយម , បឋមបញ្ញត្តិ នៃធម្មជាតិជាដើម ។

ប្រទេសដែលមានការប្រស្រ័យទាក់ទងរវាងគ្នានឹងគ្នារួមបីប្រទេស ហៅថាប្រទេសត្រៃមិត្រ បើរួមគ្នាតែពីរហៅថា ទ្វេមិត្រ ។

ប្រទេសដែលជាភាគីនៅក្នុងមិត្តភាពដូច្នេះ រមែងបាន ទទួលលទ្ធផលច្រើនប្រការ ដោយហេតុប្រទេសនានាពុំហ៊ាន មើលងាយ ។

## គ. ពាក្យពន្យល់

ប្រទេស= ន. ស្រុក, ដែន, កន្លែងទូទៅ ។

វឌ្ឍនភាព=(ម.ថ.វ័តឍៈនៈ-) ន. ដំណើរកើតកាលវាលគុំ, ភាពនៃសេចក្តីចំរើន, ការៈឬដំណើរនាំឲ្យចំរើន ។

មូលដ្ឋាន= ន. (ម.ថ.មូ-ល័តឋាន) ន. ឫសគល់, ទីតាំង

(base) ។

លទ្ធិនិយម= (ម.ថ.ល័ត-ធិ-និយំ) ន. ការកំណត់តាម
សេចក្ដីយល់ឃើញ ។

និតិន័យ= ន. លំនាំនៃច្បាប់ ។

សិទ្ធិសេរីភាព= (ម.ថ.សិត-សេរ៉ី-) ន. អំណាចនិងអំណាច
ដែលអាចធ្វើអ្វីបានតាមអំពើចិត្ត ។

អធិបតីភាព= (ម.ថ.អៈធិប៉ៈដី-) ន. ភាពនៃអ្នកដែលជាធំ ។

ធម្មសាស្ត្រ= (ម.ថ.ធ័ម-មៈសាស) ន. ច្បាប់យុត្តិធម៌

សាកល= (ម.ថ. សាកល់) គុ. ដែលទូទៅក្នុងលោក
(universel) ។

អភ័យឯកសិទ្ធិ= (ម.ថ.អ.ភៃ-ឯកៈសិត) ន. សិទ្ធិដែលជន
ខ្លះមានចំពោះខ្លួនម្នាក់ៗ មិនឲ្យមានភ័យមានទោសដល់ខ្លួន
ដូចជាមិនឲ្យគេចោទ រកចាប់ឃុំឃាំងជាដើម ។

មូលនីតិនិយម= (ម.ថ.មូលៈនីត-និយំ) ន. ការកំណត់យកច្បាប់ជាប្រសគល់ ។

បឋមបញ្ញត្តិ= (ម.ថ. ប៉ៈប័ម-ប័ញ-ញ៉ាត់) ន. សេចក្ដីដែលគេតែងតាំងជាដំបូង ។

ធម្មជាតិ្ត-ជាតិ= (ម. ថ. ធ័ម-មៈជាត) ន. ធម៌, សភាវៈ (Nature) ។

ត្រៃមិត្ត= (ម. ថ. ត្រៃ-មិត) ន. មិត្របី ។

ទ្វេមិត្ត= (ម. ថ. ទ្វេ-មិត)ន. មិត្រពីរ ។

ភាគី= ន. ចំណែក, ប៉ែក ។

មិត្តភាព= (ម. ថ. មិត-តៈភាប) ន. ភាពប្រភាវៈនៃមិត្រ, របៀបទម្រូសណ្ដាប់ធ្នាប់របស់មិត្រ(Amitié) ។

លទ្ធផល= (ម.ថ.ល័ត-ធៈផល់) ន. ផលដែលបានសម្រេចហើយ (Résultat) ។

## ៧. អក្ខរាវិរុទ្ធ

### កត់ និង គាត់

កត់= កិ. សរសេរចំណាំ ឧទា. ចូរអ្នកកត់ត្រាទុកនូវសេចក្ដីណាដែលយើងមិនទាន់យល់ច្បាស់ ៗ រាជការកត់ពន្ធអំពីអ្នកស្រុក ៗ

កត់= កិ. ចប់, ឃាត់ទុកឲ្យនៅនឹង ឧទា. ដំរីដោលគេយកកង្វៀរគាប់កត់ឲ្យនៅនឹង ៗ

គាត់= បុ. គេ, អ្នក ឧទា ម្ដាយមីងខ្ញុំ មិនបានមកទេ ព្រោះគាត់មិនសូវសប្បាយ ៗ

### កា-ការ-ការណ៍

កា= ន. បំពង់សម្រាប់ដាក់ទឹក, កំសៀវ ឧទា. នែ! ក្មេង យកកាទៅដាក់ទឹកមកផឹក ៗ

កា= កិ. សរសេរចុះឈ្មោះទីលំនៅនៅលើខ្នងសំបុត្រ

ឧទ. ការស្រោមសំបុត្រ ។

កាណ៌=(ម.ថ.កា)ន. ត្រចៀក ឧទ. ព្រះកាណ៌ព្រះរាជា ។

ការ= កិ. មួរសរសៃសូត្រ, សរសៃអំបោះ ជាដើម ដោយខ្នារ ឧទ. អ្នកត្បាញ ការសូត្រ ដើម្បីនឹងត្បាញហូល ។

ការ= កិ. បិទបាំង, រាំងរា, ឃាត់ខាំង ឧទ. ការមិនឲ្យសត្រូវចូលមក ។

ការ= ន. កិច្ចឬអំពើដែលត្រូវធ្វើ ឧទ. អ្នកអញ្ជើញមកនេះ មានការអ្វីដែរ?

ការណ៍= ន. ហេតុ, ដំណើរ ឧទ. ឯងធ្វើនេះ មុខជាទាស់ការណ៍ហើយ ។

ចប់

អនុស្សាវរីយ៍មហាវិស្សមកាល

ថ្ងៃ៥ កញ្ញា ១៩៥៦

រ.គោវិទ

# ពាក្យខុសត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| វណ្ណ | វណ្ណៈ | ២ | ១ |
| ចង់ការត្រូវដឹង | ចង់ត្រូវការដឹង | ៦ | ៩ |
| ការប្រព្រិត្ត | ការប្រព្រឹត្ត | ៨ | ៣ |
| ដើម្ប | ដើម្បី | ៨ | ១៤ |
| ក្រុលតាផាត | ក្រុលតាផាតិ | ២២ | ៧ |
| យិតយោង | យឹតយោង | ២៥ | ២ |
| ប្រពិត្ត | ប្រព្រឹត្ត | ២៩ | ១៣ |
| intelligent | intelligence | ៣៦ | ៥ |
| ផ្ទុក | ប្ញុក | ៣៩ | ៤ |
| តែកំរើក | ឥតកំរើក | ៤១ | ១១ |
| (២៣) | (២៦) | ៤២ | ១២ |
| ស្តៅស្មី | ស្មៅល្មី | ៤៥ | ៨ |

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| (ម.ជ. ដន់) | (ម.ជ. ដន) | ៥១ | ៥ |
| ពាក្យពន្យ | ពាក្យពន្យល់ | ៥៨ | ៨ |
| សេចក្ដីប្រទុស្ដិ | សេចក្ដីប្រទូស្ដ | ៦៨ | ៨ |
| កាន់ប្រយោជន៍គេ | កាត់ប្រយោជន៍គេ | ៧៨ | ៩ |
| ឆ្ឈិត | ភ្ឈិត | ៧៩ | ៦ |
| រកាហាត់ | ការហាត់ | ៩០ | ៣ |
| ឧតុង្គឧត្តម | ឧត្តុង្គឧត្តម | ៩១ | ៣ |
| ជ្រុំជ្រៃង | ជ្រោមជ្រៃង | ១០២ | ១០ |
| អត្ថបទលេខ ២៣ | អត្ថបទលេខ ១៨ | ១០៥ | ១០ |
| អត្ថបទលេខ ២៧ | អត្ថបទលេខ ២២ | ១១១ | ៩ |
| អត្ថបទលេខ ២៣ | អត្ថបទលេខ ១៨ | ១១១ | ១១ |
| អត្ថបទលេខ ១៤ | អត្ថបទលេខ ៩ | ១២២ | ៨ |
| អត្ថបទលេខ ១៦ | អត្ថបទលេខ ១១ | ១២៦ | ១៤ |
| ឧតុង្គឧត្តម | ឧត្តុង្គឧត្តម | ១២៨ | ៣ |

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| គុណជាតិឬគុណជាតិ | គុណជាតិឬគុណជាត | ១២៨ | ៤ |
| អត្ថបទលេខ ២៨ | អត្ថបទលេខ ២៣ | ១៣២ | ១១ |
| moralie | morale | ១៥៩ | ៦ |
| ៣៥ និញ្ញាន | ៣៤ និញ្ញាន | ១៦១ | ១ |
| ៣៤អធ្យាស្រ័យ... | ៣៥អធ្យាស្រ័យ... | ១៦៦ | ១ |
| ធម្មជាតិឬ–ជាតិ | ធម្មជាតិឬ–ជាត | ១៩៣ | ៦ |
| លទ្ធផល | លទ្ធផល | ១៩៣ | ១៣ |

# ផ្សាយចេញពីបណ្ណាគាររស្មីកម្ពុជា

លោកនីតិ (គឹម-សែត)

អត្ថវិនិច្ឆ័យតាមវេយ្យាករណ៍ (គឹម-សែត)

វចនានុក្រមខ្មែរបារាំងភាគ ១-២ (រ-គេរិច)

វេយ្យាករណ៍ដោយរូបភាព (ឌុ. គាមមុនី)

៤០សរសេរតាមសូត្រ (រ. គេរិច)

## កំពុងបោះពុម្ព

ភាសាបារាំង (Methode pratique de langage et de lecture (A.B.C.) (គឹម-សែត)

(Lecture française expliquée en cambodgien (គឹម-សែត)

អត្ថបទសំរាំងថ្នាក់ឧត្តមដ្ឋាន (គឹម-សែត)

វេយ្យាករណ៍អង់គ្លេសពន្យល់ជាភាសាខ្មែរ (ប្រសិដ្ឋបញ្ញាំងចិត្រ)

ភាសាអង់គ្លេសឆាប់ (ប្រសិដ្ឋបញ្ញាំងចិត្រ)

លោកខ័យសាស្ត្រ (មាស-ព្រេង)